ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ស.ភ.ន.វ.ស
ដេប៉ាតឺម៉ង់គណនេយ្យ
និងគ្រប់គ្រង


# វិធីសាស្ត្របង្រៀននៅថ្នាក់ឧត្តមសិក្សា

ករណីសិក្សាលើការបង្រៀនរបស់សាស្ត្រាចារ្យ
នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Method of teaching in Higher Education

Cas Study: Lecture’s method of teaching at RULE


**បណ្ឌិត ចាន់ ស៊ុនដេត**


មករា ឆ្នាំ ២០១៨

# អារម្ភកថា

ការបង្រៀនគឺជាសិល្បៈនៃការផ្ទេរចំណេះវិជ្ជាពីអ្នកមានចំណេះច្រើនទៅអ្នកមិនទាន់ចេះមានដូចជា ការអាន ការសរសេរ និងការគិត និយាយជារួមពីគ្រូទៅសិស្ស ពីព្រោះគ្រូមានចំនុចទាំងអស់នេះ។ ការផ្ទេរមានន័យថាជាការយកអ្វីមួយចេញពីក្នុងអ្វីមួយទៅដាក់ក្នុងអ្វីមួយផ្សេងទៀត ដូចជាការផ្ទេរទឹកស្អាតចេញពីកែវធំមានទឹកច្រើនដាក់ទៅដាក់ក្នុងកែវល្អ ស្អាតដើម្បីរក្សាទុកញ៉ាំ។ យ៉ាងណាមិញ ការផ្ទេរវិជ្ជាទាំងឡាយ គ្រូគប្បីពិចារណារកវិធីបង្រៀនណាមួយដែលសមស្រប ដែលអាចអនុវត្តបានជាមួយសិស្សនៅក្នុងថ្នាក់ដើម្បីឲ្យកិច្ចដំណើរការបង្រៀនប្រព្រឹត្តទៅទទួលបានលទ្ធផលល្អ។ ការមានវិធីបង្រៀនតែមួយមិនគ្រប់គ្រាន់ឡើយ ពីព្រោះសមត្ថភាពសិស្សមិនដូចគ្នា ការទទួលយកវិជ្ជាពីគ្រូដែលបាននិងកំពុងផ្ទេរក៏មិនដូចគ្នាដែរ។ សិស្សដែលមានបញ្ញាល្អ ពូកែអាចទទួលយកវិជ្ជាបានភ្លាមៗ ប៉ុន្តែសិស្សដែលមានបញ្ញាមិនសូវពូកែមិនអាចទទួលយកបានភ្លាមទេលុះត្រាតែមានវិធីបង្រៀនផ្សេងទៀត។ មានករណីសិក្សាដូចជាសិស្សខ្លះស្តាប់តែគ្រូពន្យល់ គឺអាចយល់ខ្លឹមសារមេរៀនបានភ្លាមដោយសារសោតប្បសាទទទួលសម្លេងគ្រូពន្យល់បានល្អ ពួកគាត់ឆាប់យល់ ។ ប៉ុន្តែមានសិស្សមួយក្រុមទៀត អាចយល់ខ្លឹមសារមេរៀនបានដ៏រាបណាមើលឃើញរូបភាពកាយវិការបន្ថែមទៀតទើបគាត់យល់។ សរុបសេចក្តីមកការងារបង្រៀនត្រូវមានវិធីបង្រៀនសម្បូរបែប និងអាចបត់បែនទៅតាមស្ថានភាព សមត្ថភាពសិស្សទើបការបង្រៀនទទួលបានជោគជ័យនៅក្នុងវិស័យសិក្សាអប់រំ។

# មាតិកាស្រាវជ្រាវ


I . **សេចក្តីផ្តើម** ............................................................ ៦

1. លំនាំបញ្ហា ............................................................ ៦
2. បញ្ហាស្រាវជ្រាវ ............................................................ ៦
3. សំណួរស្រាវជ្រាវ ............................................................ ៦
4. សារៈសំខាន់នៃការស្រាវជ្រាវ ............................................................ ៦
5. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............................................................ ៧

I I . **សិក្សាទស្សនៈ និងទ្រឹស្តីនៃការបង្រៀន** ............................................................ ៧

1. និយមន័យនៃការបង្រៀន ............................................................ ៧
2. ទ្រឹស្តីគរុកោសល្យមួយចំនួន ............................................................ ៩
3. វិធីបង្រៀន ............................................................ ១៣
4. គ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល ............................................................ ១៤
5. ការរៀបចំមេរៀនលម្អិតសម្រាប់បង្រៀន ............................................................ ១៥
6. បរិស្ថានថ្នាក់រៀន ............................................................ ១៦
7. សារៈសំខាន់នៃវិធីបង្រៀន ............................................................ ១៦

III. **វិធីសាស្ត្រស្រាវជ្រាវ** ............................................................ ១៩

1. ការកំណត់វិធីសាស្ត្រ ............................................................ ១៩
2. ការបង្ហាញលទ្ធផលបន្តបន្ទាប់នៃសំណួរស្រាវជ្រាវ ............................................................ ១៩

IV. **លទ្ធផលស្រាវជ្រាវ** ............................................................ ៣៦

1. វិធីទី១ ............................................................ ៣៧
2. វិធីទី២ ............................................................ ៣៨

V. **សេចក្តីសន្និដ្ឋាន** ............................................................ ៣៩


**ចំនួនតារាង**


តារាងទី១ ............................................................ ២០
តារាងទី២ ............................................................ ២០
តារាងទី៣ ............................................................ ២១
តារាងទី៤ ............................................................ ២១
តារាងទី៥ ............................................................ ២២
តារាងទី៦ ............................................................ ២៣
តារាងទី៧ ............................................................ ២៣

តារាងទី៨ ..................................................................................................... ២៤
តារាងទី៩ ..................................................................................................... ២៥
តារាងទី១០..................................................................................................... ២៥
តារាងទី១១..................................................................................................... ២៦
តារាងទី១២ ..................................................................................................... ២៧
តារាងទី១៣ ..................................................................................................... ២៧
តារាងទី១៤..................................................................................................... ២៨
តារាងទី១៥..................................................................................................... ២៩
តារាងទី១៦..................................................................................................... ២៩
តារាងទី១៧ ..................................................................................................... ៣០
តារាងទី១៨..................................................................................................... ៣១
តារាងទី១៩..................................................................................................... ៣២
តារាងទី២០ ..................................................................................................... ៣៣
តារាងទី២១ ..................................................................................................... ៣៣
តារាងទី២២ ..................................................................................................... ៣៤
តារាងទី២៣..................................................................................................... ៣៥
តារាងទី២៤ ..................................................................................................... ៣៦
តារាងទី២៥ ..................................................................................................... ៣៦
តារាងទី២៦ ..................................................................................................... ៣៧
តារាងទី២៧..................................................................................................... ៣៨
តារាងទី២៨ ..................................................................................................... ៣៩
ក្រាភិកទី១..................................................................................................... ៣៩
ឯកសារយោង ..................................................................................................... ៣០
ឧបសម្ព័ន្ធ..................................................................................................... ៤១

# I. សេចក្តីផ្តើម

## 1. លំនាំបញ្ហា

ការសិក្សា គឺជាយន្តការមួយសម្រាប់អភិវឌ្ឍន៍កំណើនសេដ្ឋកិច្ច និង សង្គម។ ការសិក្សាមិនត្រឹមតែផ្តល់ចំណេះដឹង ជំនាញ និងគុណតម្លៃនៃការបណ្តុះគំនិតបណ្តុះនិស្ស័យទេ ប៉ុន្តែវាទទួលខុសត្រូវក្នុងការបង្កើតមូលធនមនុស្ស ដែលបណ្តាលឲ្យមានចលនា ធ្វើឲ្យដំណើរការ និងរៀបចំនវានុវត្តបច្ចេកវិទ្យា និងកំណើនសេដ្ឋកិច្ចថែមទៀត។ ដូច្នេះការស្វែងរកវិធីនៃការបង្រៀនដើម្បីផ្ទេរចំណេះទាំងនោះទៅនិស្សិត ជាកិច្ចការមួយដែលតម្រូវឲ្យអ្នកបង្រៀន ជាពិសេសគ្រូ ត្រូវមានសមត្ថភាពគ្រប់គ្រាន់ និងបច្ចេកទេសផ្សេងៗ ឬ ឧបករណ៍/សម្ភារៈឧបទ្ទេសសិក្សា ដើម្បីបង្កភាពងាយស្រួលដល់ការផ្ទេរចំណេះដឹងដល់សិស្ស និស្សិត។ ការសិក្សានៅថ្នាក់ឧត្តមសិក្សាមានលក្ខណៈស៊ីជម្រៅលើជំនាញ និងសមត្ថភាពក្នុងការធ្វើ។ ដូច្នេះវាទាមទារឲ្យអ្នកបង្រៀនត្រូវមានវិធីសាស្រ្តជាក់លាក់ សមស្របទៅនឹងភាពបត់បែននៃជំនាញនីមួយៗ ដែលធ្វើឲ្យនិស្សិតអាចឆាប់យល់ និងទទួលបានចំណេះដឹង។

## 2. បញ្ហាស្រាវជ្រាវ

គម្រោងស្រាវជ្រាវនេះបានផ្តោតលើបញ្ហាមួយចំនួនដូចខាងក្រោម ៖

- ការប្រើប្រាស់ទ្រឹស្តីគរុកោសល្យនៅពេលបង្រៀន
- វិធីសាស្រ្តបង្រៀនផ្សេងៗ
- កិច្ចតែងការសម្រាប់ការបង្រៀន
- ការប្រើប្រាស់សម្ភារៈឧបទ្ទេសនៅពេលបង្រៀន

## 3. សំណួរស្រាវជ្រាវ

និស្សិតដែលសិក្សានៅវិទ្យាស្ថានក្តី នៅសាកលវិទ្យាល័យក្តី តែងតែចង់បានការបង្រៀនរបស់គ្រូឲ្យឆាប់យល់ ឆាប់ចេះលើមុខវិជ្ជាដែលត្រូវ ឬកំពុងសិក្សា។

តើវិធីបង្រៀនបែបណាដែលធ្វើឲ្យនិស្សិតងាយយល់?

## 4. សារៈសំខាន់នៃការស្រាវជ្រាវ

គម្រោងស្រាវជ្រាវនេះផ្តល់សារៈសំខាន់លើការបង្រៀនក្នុងន័យ ៖

- ជាទស្សនៈណែនាំ និងឧបករណ៍គន្លឹះសម្រាប់ប្រើប្រាស់ក្នុងការផ្តល់សេវាបង្រៀនកម្រិតអប្បបរមាមួយសម្រាប់ឧត្តមសិក្សា។

– សម្រាប់ជ្រើសរើស វិភាគ អភិវឌ្ឍ ប្រើប្រាស់និងវាយតម្លៃកិច្ចការបង្រៀន ឲ្យបានសមស្របជាមួយស្ថានភាពសង្គម។

**5. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ការស្រាវជ្រាវនេះ គឺស្វែងរកវិធីបង្រៀនល្អ និងអាចឆ្លើយតបទៅនឹងការចង់ចេះ ចង់ដឹងរបស់និស្សិត។ ទំហំនៃការសិក្សាស្រាវជ្រាវផ្តោតលើ វិធីបង្រៀនរបស់គ្រូដែលកំពុងបង្រៀននៅមហាវិទ្យាល័យ ឬ សាកលវិទ្យាល័យ។

# II. សិក្សាទស្សនៈ និងទ្រឹស្តីនៃការបង្រៀន

ការបង្រៀនជាសកម្មភាពមួយកើតឡើងច្រំដែលម្តងហើយម្តងទៀត។ ដើម្បីឲ្យការបង្រៀនមួយស័ក្តិសិទ្ធ ចៀសវាងការមិនសូវស៊ីចង្វាក់ និងកាត់បន្ថយកំហុសជាយថាហេតុខ្លះៗនៅពេលបង្រៀន តាមទស្សនៈ (Hildebrand 1971) ចែកចេញជាពីរចំនុចសំខាន់៖ ទី១ ការចាត់ចែង និង ភាពច្បាស់លាស់ ៖ ការបង្រៀនត្រូវពន្យល់ឲ្យច្បាស់លាស់ ត្រូវរៀបចំកិច្ចតែងការបង្រៀនជាពិសេសនៅថ្ងៃបង្រៀនដំបូង ប្រធានបទពិបាកធ្វើឲ្យងាយយល់ ប្រើឧទាហរណ៍ច្រើន លម្អិត ស្រដៀងៗគ្នា ប្រៀបធៀប និងភាពប្លែកៗនៅក្នុងវិធីបង្កើតសម្ភារៈសម្រាប់បកស្រាយពន្យល់ មិនអាចធ្វើឲ្យយល់ដោយគ្រាន់តែរំលឹកការចងចាំតែមួយមុខបានទេ បង្កើតកម្មវត្ថុសម្រាប់មេរៀន និងច្បាស់លាស់សម្រាប់ថ្នាក់នីមួយៗ(រៀបចំគម្រោងមេរៀន កម្មវត្ថុ និងលទ្ធផលសិក្សា) និងធ្វើនិទស្សន៍បរិបទណាមួយដើម្បីប្រើឧបករណ៍បង្រៀន។ ទី២ វិធីវិភាគសំយោគ ៖ ដាក់វិន័យឲ្យបានហ្មត់ចត់សម្រាប់ដំណើរការសិក្សា ផ្តល់ភាពទាក់ទងផ្សេងៗគ្នាសម្រាប់ទ្រឹស្តីនីមួយៗ ផ្តល់ការយល់ដឹងដល់និស្សិតសម្រាប់ដំណើរការសិក្សាពីអតីតកាល បច្ចុប្បន្នកាល និងទិសដៅទៅអនាគតកាល ពីប្រភពដើមនៃគំនិត និងទស្សនៈ។ ដូច្នេះដើម្បីឲ្យការបង្រៀនបានល្អ គ្រូដែលមានសមត្ថភាពខ្ពស់ត្រូវចេះបំផុសគំនិត បង្កើតការច្នៃប្រឌិត មានភាពម៉ឺងម៉ាត់ និងមានការប្តេជ្ញាខ្ពស់។

1) និយមន័យនៃការបង្រៀន គឺជាសកម្មភាពពីរកើតឡើងព្រមគ្នាស្តីពីសកម្មភាពគ្រូ និងសកម្មភាពសិស្ស។ គ្រូបំផុសគំនិត្យឲ្យសិស្សស្គាល់តម្លៃនៃចំណេះ បញ្ញាតាមវិធីសិល្បៈដើម្បីឲ្យសិស្សដក់ជាប់នៅក្នុងចិត្តនិងស្មារតី។ ទាក់ទងនឹងការបង្រៀនដែលមានការទទួលខុសត្រូវខ្ពស់នេះ John Steinbeck បានកំណត់ថា « *ការបង្រៀនជាសិល្បៈដ៏អស្ចារ្យបំផុតមួយ ពីព្រោះវាជាបណ្តាញផ្សព្វផ្សាយដែលអាចផ្លាស់ប្តូរផ្នត់គំនិត និង ស្មារតីមនុស្ស* »

(Robert Smith, Ph.D. & Scott Imig, Ph.D. 2014)។ ការណ៍នេះមានន័យថារាល់ទស្សនៈ ឬជំនាញដែលគ្រូពន្យល់ដល់សិស្សរាប់ចាប់តាំងពីការបញ្ចេញសម្លេង កាយវិការ ទឹកមុខ និងសកម្មភាពភ្ជាប់ជាមួយដទៃទៀត បានជិតជាប់នៅក្នុងចិត្ត និងស្មារតីរបស់សិស្សជានិច្ច។ ហេតុនេះគ្រូត្រូវធ្វើជាគំរូល្អ ជាពិសេសរៀបចំពូកពារ ចរិយាសម្បត្តិឲ្យបានសមរម្យ។ ម្យ៉ាងទៀតដើម្បីឲ្យការបង្រៀនមានប្រសិទ្ធភាព (Hattie 2017)មានប្រាំវិធី ទី១ ភាពច្បាស់លាស់របស់គ្រូ គឺនៅពេលចាប់ផ្តើមបង្រៀនមេរៀនថ្មី ឬគម្រោងថ្មីសម្រាប់និស្សិត គ្រូត្រូវបង្ហាញគោលបំណងច្បាស់លាស់និងសិក្សាគោលដៅ និងផ្តល់លក្ខណៈវិនិច្ឆ័យជាក់លាស់យ៉ាងណាដែលនិស្សិតអាចទទួលបានជោគជ័យ។ ទី២ ការពិភាក្សានៅក្នុងថ្នាក់ គឺគ្រូត្រូវការការចូលរួមឲ្យបានញឹកញាប់ពីនិស្សិតទាំងក្រោមឆាក និងផ្តល់ភាពងាយស្រួលដល់ការពិភាក្សានៅក្នុងថ្នាក់ ។ ការណ៍នេះនិស្សិតត្រូវសិក្សាពីបញ្ហាផ្សេងៗឲ្យបានច្រើន។ វាជាឱកាសយ៉ាងប្រសើរសម្រាប់គ្រូស្ទង់ប៉ាន់មើលការចាប់យកសេចក្តីពេញចិត្ត និងគំនិតថ្មីរបស់និស្សិតម្នាក់ៗ។ ទី៣ ព័ត៌មានផ្តល់មកឲ្យវិញ តើធ្វើយ៉ាងណាដឹងការរំជួលចិត្តយ៉ាងពិតប្រាកដទៅខាងមុខ ដោយមិនផ្លាស់ប្តូរព័ត៌មានផ្តល់ត្រឡប់មកវិញ? ជារឿយៗគេមិនត្រូវការព័ត៌មានផ្តល់ត្រឡប់មកវិញជាឯកជនទេ គ្រូត្រូវការព័ត៌មានផ្តល់ត្រឡប់មកវិញពីក្រុមទាំងមូលនៅលើគំរូដែលពិនិត្យឃើញថាជាដំណោះស្រាយរួមនៅក្នុងថ្នាក់ដើម្បីឲ្យមានការរីកចម្រើន និងតម្រូវទៅតាមវិស័យនីមួយៗ។ ទី៤ ទម្រង់វាយតម្លៃ មានន័យថា ដើម្បីនឹងផ្តល់ឲ្យនិស្សិតមានប្រសិទ្ធភាព និងព័ត៌មានផ្តល់ត្រឡប់មកឲ្យវិញទៀងទាត់ គ្រូត្រូវស្ទង់ប៉ាន់មើលភាពញឹកញាប់ និងធ្វើតាមទម្លាប់ដដែលៗ ដែលនិស្សិតមានទំនាក់ទំនងទៅក្នុងវគ្គនៃការសិក្សាគោលដៅជ្រៅជ្រះ ឬលទ្ធផលចុងបញ្ចប់(ការវាយតម្លៃបញ្ចប់វគ្គសិក្សា)។ ហេតុនេះគ្រូគួរចំណាយពេលខ្លះរៀបចំទម្រង់ការសម្រាប់វាយតម្លៃដើម្បីធ្វើការវាយតម្លៃបញ្ចប់វគ្គសិក្សា។ ទី៥ វិធីស្វែងយល់ការយល់ដឹងរបស់និស្សិត គឺនិស្សិតត្រូវបានផ្តល់ឱកាសឲ្យរៀបចំផែនការ និងចាត់ចែងឧបករណ៍សម្រាប់សង្កេតផ្ទាល់ខ្លួនរបស់ពួកគេ ការសិក្សាជ្រៅជ្រះផ្ទាល់ខ្លួនរបស់ពួកគេ និងការជញ្ជឹងគិតដោយខ្លួនឯងទៅតាមវិធីសាស្ត្រឬផែនការ។ នៅពេលដែលយើងផ្តល់ឲ្យនិស្សិតនូវពេលវេលាកំណត់សម្រាប់ការយល់ដឹងផ្ទាល់ខ្លួនរបស់ពួកគេ និងការគិតពិចារ ណាផ្ទាល់ខ្លួនរបស់ពួកគេ នោះចំណេះដឹងផ្ទាល់ខ្លួនរបស់និស្សិតមានការកើនឡើង។ ទាក់ទងនឹងការបង្រៀននេះដែរ ការស្រាវជ្រាវរបស់ (Stremmel 2002)បានបង្ហាញ

ថាគរុនិស្សិត[1]ឬគ្រូបង្រៀនថ្មីមានទំនោរជឿទៅលើ« សំណុំចម្លើយមេរៀនខ្លះដែលត្រឹមត្រូវ» ចំពោះចំណោទ ឬមេរៀនសម្រាប់បង្រៀន និងពួកគេយល់ឃើញរូបភាព ប្រៀបដូចជាអ្នកប្រើប្រាស់និងអ្នកចែកចាយព័ត៌មានផលិតផលដូច្នេះដែរ។ ដូច្នេះ ការធ្វើសកម្មភាពស្រាវជ្រាវបានជួយចម្រាញ់យកការរិះរកហេតុផល មានន័យថាបង្កើនចំណេះដឹងដល់គ្រូបង្រៀន និងការយល់ដឹងជ្រៅជ្រះអំពីការបង្រៀន និងការសិក្សា។ ការព្យាយាមស្រាវជ្រាវ បង្កើនចំណេះដឹងថ្មី ឬអ្វីៗដែលជាចំណេះដឹងក្នុងតំបន់ គឺដើម្បីដោះស្រាយការបង្រៀន និងការសិក្សាដែលត្រូវចែករំលែកនិងជម្រុញការអនុវត្តនៅក្នុងថ្នាក់។ បន្ថែមពីនេះ ការបង្រៀនគឺជាការអនុវត្តប្រសើរនៅពេលដែលចេះធ្វើការអង្កេត និង គ្រូចេះស្រាវជ្រាវដោយប្រើប្រាស់តាមរបៀបបច្ចេកទេសអង្កេត។ ការកំណត់លក្ខណៈពិសេសនៃគ្រូស្រាវជ្រាវគឺគ្រូបំពេញមុខងារពីរ ទី១ ជាអ្នកប្រកបវិជ្ជាជីវៈបង្រៀន និងទី២ ជាអ្នកស្រាវជ្រាវនៅក្នុងថ្នាក់ដែលជាអ្នកវិទ្យាសាស្ត្រនិយម និងជាអ្នកស្រាវជ្រាវនៃវិស័យអប់រំ។ គ្រូជួបប្រទះបញ្ហាជាក់ស្តែង ឧបសគ្គបទពិសោធន៍ដើម្បីយល់ និងពិចារណារាល់ថ្ងៃដើម្បីឲ្យការគិតគឺដូចគ្នានឹងអ្វីដែលកើតមានឡើង។

2) ទ្រឹស្តីគរុកោសល្យមួយចំនួនពាក់ព័ន្ធនឹងការបង្រៀនរបស់គ្រូ មានដូចជា

- **វិធីអនុមានរួម ឬ វិធីអនុលោម** (Inductive)គឺជាការកំណត់ មានដូចជាសំណុំបែបបទនៃការព្យាយាមបញ្ជូនចំណេះដឹងជាច្រើនប្រភេទ នៅពេលកំពុងដំណើរការនៃការបង្រៀន បញ្ញានៃការគិតពិចារណា តម្រង់ទិសពីហេតុការណ៍ ឆ្ពោះទៅរកសភាពទូទៅ (Forms and Methods of Teaching in Higher Education Institutions)។ មានន័យថា បង្ហាញពីសភាព ឬគំនិតជាក់លាក់ទៅជាគំនិតទូទៅ។ ជាងនេះទៀត វិធីអនុលោមមានន័យថាធ្វើការបញ្ជូនពីហេតុការណ៍មួយទៅកាន់តួនាទីខ្ពស់ជាងណាមួយ ឬ ផ្តល់ឲ្យទ្រង់ទ្រាយគំនិតរៀបរយដែលទូទៅមួយ (Laursen 2017)។ វិធីអនុលោមគឺឈានទៅរកការសន្និដ្ឋាន ឬ សេចក្តីសង្ខេបសម្រាប់ស្វែងយល់ឧទាហរណ៍ ឬ ការអង្កេតណាមួយដែលផ្តល់ឲ្យ។ ហេតុនេះវិធីអនុលោមជាវិធីប៉ងប្រាថ្នាមួយ ដើម្បីឈានទៅដល់ការយល់ដឹងទូទៅដោយសង្ខេបការអង្កេតនានាដែលជាឱកាសនៃឧប្បត្តិហេតុ ឬ ព្រឹត្តិការណ៍ដែលកើតមានឡើង។

[1] និស្សិតដែលរៀនច្បាប់គរុកោសល្យដើម្បីក្លាយជាគ្រូបង្រៀនឈ្លៀសវៃនៅពេលខាងមុខ

• **វិធីអនុមានញែក ឬ វិធីបដិលោម** (Deductive)គឺជាការកំណត់ មានដូចជាសំណុំបែបបទនៃការព្យាយាមបញ្ជូនប្រភេទជាច្រើននៃចំណេះដឹង ដែលបង្ហាញពីដំណើរនៃភាពជាក់លាក់(Logical) ពីរបកគំហើញចំណេះដឹងថ្មី(Discovering)នៅលើមូលដ្ឋានចំណេះដឹងទូទៅ (Forms and Methods of Teaching in Higher Education Institutions)។ មានន័យថាចេញដំណើរពីគំនិតទូទៅ ទៅជាគំនិតច្បាស់លាស់។ បន្ថែមលើចំនុចនេះ ការបកស្រាយរបស់ (Laursen 2017)ថា មានលក្ខណៈផ្ទុយពីគំនិតអនុលោម។ ជាមួយភាពជឿជាក់ណាមួយ វាអាចព្យាករណ៍បានលទ្ធផលមួយ ដោយផ្លាស់ពីគោលការណ៍ទៅជាឧប្បត្តិហេតុ និងពីឧប្បត្តិហេតុទៅជាលទ្ធផលបន្តបន្ទាប់។ វិធីអនុមានញែកជាផ្លូវដោះស្រាយឬខិតទៅជិតសេចក្តីសន្និដ្ឋានដែលមើលទៅហាក់ដូចជាបញ្ញត្តិទូទៅ ជាទ្រឹស្តី ឬជាសម្មតិកម្ម។ វិធីអនុមានញែកបង្កើតឲ្យមានការចោទសួរដើម្បីធ្វើឲ្យស្ងប់ចម្ងល់ សម្រាប់ធ្វើត្រាប់តាម ឲ្យធ្វើតាមបង្គាប់បញ្ជា ធ្វើការបញ្ចុះបញ្ចូល ធ្វើឲ្យមានព្រំដែនស្មើគ្នាជាគ្រូមជ្ឈមណ្ឌលនៅក្នុងស្ថានភាពមួយគ្មានតុល្យភាព។ រីឯវិធីអនុមានរួម ឬ វិធីអនុលោមត្រូវបានលើកសរសើរ ធ្វើឲ្យមានសកម្មភាពកើតឡើង ធ្វើឲ្យមានស្មារតីឡើង មានលក្ខណៈជាសិស្សមជ្ឈមណ្ឌលមានការលើកទឹកចិត្តជាដើម។ បន្ថែមលើគំនិតនេះ (Thiyagu 2011) បកស្រាយថា វិធីអនុមានញែកគឺអាស្រ័យលើការអប់រំ។ វាជាវិធីមួយបង្រៀនពីលក្ខណៈទូទៅឲ្យទៅជាលក្ខណៈពិសេស និងពីអរូបីទៅរូបី។ ជាដំបូង គោលការណ៍គឺផ្តល់ឱកាសឲ្យសិស្សសួរសំណួរ និងបន្ទាប់អនុវត្តដោះស្រាយចំណោទផ្សេងៗពីគ្នាឲ្យបានច្រើន។ វិធីនេះជួយឲ្យមានការជជែកវែកញែកពីការសន្មតនានា ពីការកំណត់សម្មតិកម្ម និងពីស្វ័យសត្យ(Axioms)នៃមុខវិជ្ជា។ វិធីអនុមានញែកបណ្តាលមកពីគោលការណ៍ទូទៅ ទៅជាករណីពិសេសតែម្តង ពីការមិនយល់ទៅជាយល់ ពីគោលការណ៍អរូបីទៅគោលការណ៍រូបីតែម្តង ពីសាំញ៉ាំទៅងាយស្រួល។ ដើម្បីឲ្យការបង្រៀនតាមវិធីអនុមានញែកសក្តិសិទ្ធធ្វើតាមជំហានបន្តបន្ទាប់ ទី១ យល់ឬដឹងច្បាស់នៃបញ្ហា ទី២ ស្រាវជ្រាវសម្រាប់សម្មតិកម្មសាកល្បង ទី៣ បង្កើតរូបមន្តឬគំរូនៃសម្មតិកម្មសាកល្បង ទី៤ ការផ្ទៀងផ្ទាត់ ឬត្រួតពិនិត្យមើល។

• **វិធីចំរុះ** គឺមានសារៈសំខាន់យ៉ាងខ្លាំងស្តីពីរបៀបសិក្សានៃការអប់រំស្រាវជ្រាវ។ ការបង្រៀនមេរៀនផ្តល់ឲ្យនិស្សិតនូវឱកាសសម្រាប់ដោះស្រាយបញ្ហាជាមួយការផ្លាស់ប្តូរនៃកិច្ចការប្រតិបត្តិក្នុងការសិក្សាតាមបែបវិធីសាស្ត្រចំរុះ (Robert G. Croninger

& Linda Valli 2012)។ និស្សិតអាចនឹងត្រួតពិនិត្យការយល់ដឹងស្របជាមួយទស្សនៈទូទៅ (epistemological) និងបញ្ហាវិធីសាស្ត្រដែលពាក់ព័ន្ធនឹងកិច្ចការសិក្សា។ ការងារជាលក្ខណៈឯកជន ឬ ការងារជាក្រុមតូចៗ និស្សិតអាចរចនា និងធ្វើការវិភាគទិន្នន័យដែលមានស្រាប់រួមមានទិន្នន័យជាគុណវិស័យ (qualitative) និងជាបរិមានវិស័យ (quantitative) ក្នុងការបង្រៀនបែបគណិតវិទ្យា និងលើការអានអត្ថបទ ឬ ឯកសារសិក្សាផ្សេងៗ។ ម្យ៉ាងទៀតវិធីចំរុះគឺជាការរួមបញ្ចូលគ្នារវាងរវាងទស្សនៈអនុលោម/អនុមានរួមនិងបដិលោម/អនុមានញែក (ប្រាជ្ញពិជ័យ និង ឌុំដារុធ ២០១៥)។ ការធ្វើបែបនេះនាំឲ្យចំណេញពេលច្រើនក្នុងការបង្រៀនរបស់គ្រូដោយគ្រាន់តែធ្វើការស្វែងយល់នូវទ្រឹស្តីដែលមានស្រាប់ ធ្វើតាមការពិសោធន៍នូវអ្វីដែលគេបានធ្វើរួចហើយឲ្យបានច្បាស់លាស់ ត្រឹមត្រូវតាមរូបមន្ត តាមទ្រឹស្តីដែលបានពិសោធន៍ចប់សព្វគ្រប់អស់ហើយនោះគឺជាការស្រេច និងមិនចាំបាច់ចំណាយពេលធ្វើការសាកល្បង ឬធ្វើការពិសោធន៍ឡើងវិញទេ។ ការបង្រៀនតាមវិធីចំរុះគ្រូមានសេរីភាពគ្រប់គ្រាន់ក្នុងសកម្មភាពបង្រៀន។ ដូច្នេះសេរីភាពក្នុងការជ្រើសរើសវិធីបង្រៀនវាមានសារៈសំខាន់ដែលគ្រូត្រូវការមុន។ សេរីភាពនៃការជ្រើសរើសវិធីបង្រៀនគឺមានសារៈសំខាន់ពីព្រោះវាធ្វើឲ្យគ្រូបង្រៀនមានឱកាសដើម្បីស្វែងរកទ្រឹស្តីខ្លះៗសម្រាប់គោលមេរៀន ដែលត្រូវបង្រៀនរយៈពេលវែង នៅក្នុងការជួបជាមួយនិស្សិតរបស់គាត់នៅក្នុងរយៈពេលនៃការសិក្សា។ ការរៀបចំគោលអត្ថបទបង្រៀននេះអាចជាការណែនាំណាមួយចេញពីគំនិតដែលកើតមានឡើងចំពោះគ្រូ ឬ ពីនិស្សិត ។ មធ្យោបាយនៃការចូលរួមរបស់និស្សិតនៅក្នុងការសម្រេចចិត្តគឺជាការត្រិះរិះដោយគោរព ដោយសេចក្តីពេញចិត្តផងដែរ។

**វិធីចំរុះ**
ការបង្រៀន និងការសិក្សាអាស្រ័យលើគោលការណ៍ដែលអ្នកសិក្សាជួយខ្លួនឯងឲ្យរីកចំរើនឡើងជាមួយសម្មតិកម្ម ការបកស្រាយ ឬ គំរូនៃដំណោះស្រាយចំណោទដែលអាចមានចម្លើយចំពោះចំណោទជាក់លាក់ ការផ្តល់យោបល់ជំទាស់ ឬសំណើ។

**វិធីអនុលោម:** ការបង្រៀន និងការសិក្សាអាស្រ័យលើគោលការណ៍ ដែលអ្នកសិក្សាយកចំណេះដឹង និងការទទួលស្គាល់ពីបទពិសោធន៍ផ្ទាល់ខ្លួនចំពោះប្រធានបទ។ នេះអាចកើតមានឡើងតាមរយៈបទពិសោធន៍នានាពីអតីតកាល ឬតាមរយៈបទពិសោធន៍នានា និងការពិសោធន៍នានាដែលបង្កើតឡើងនៅក្នុងបរិដ្ឋានសិក្សាជាលាក់មួយ។ ការសន្និដ្ឋាននិងករណីទូទៅត្រូវបានបង្កើតចេញពីបទពិសោធន៍ពិសេសទៅជាចំណេះដឹងទូទៅ។

**វិធីបដិលោម:** ការបង្រៀន និងការសិក្សាអាស្រ័យលើគោលការណ៍ ដែលអ្នកសិក្សាត្រូវដាក់ទៅជាច្បាប់ ជាគោលការណ៍ ឬ ជាទ្រឹស្តីជាមួយសេចក្តីព្យាយាម ប៉ងប្រាថ្នាដើម្បីបង្កើនការយល់ដឹងរបស់គាត់ សម្រាប់ប្រធានបទ ឬ វាល(field)។ ចំណេះដឹងជាក់លាក់ត្រូវបានទាញចេញពីច្បាប់ទូទៅ ឬ ពីគោលការណ៍ទូទៅ។

( ប្រភព www.abduktiv.dk )

- ការគ្រប់គ្រងថ្នាក់ គឺមានសារ:សំខាន់ខ្លាំង។ បើនៅក្នុងថ្នាក់រៀនសិស្សគ្មានវិន័យការបង្រៀនរបស់គ្រូគ្មានប្រយោជន៍អ្វីទេ។ នៅក្នុងថ្នាក់រៀនគ្រូមានភារ:កិច្ចនិងដើរតួនាទីសំខាន់ក្នុងការដឹកនាំការបង្រៀនឲ្យបានល្អ។ ការគ្រប់គ្រងថ្នាក់រៀនជាពាក្យដែលប្រើដោយគ្រូបង្រៀន ដើម្បីពិពណ៌នាដំណើរការបង្រៀនសម្រាប់ធានាឲ្យប្រាកដថាការបង្រៀនប្រព្រឹត្តទៅយ៉ាងរលូន ទោះបីមានអាកប្បកិរិយារំខានដោយនិស្សិតក៏ដោយ។ ទស្សន:របស់ Bellon, Bellon, & Blank(1992) ពាក្យថា «*ការគ្រប់គ្រងថ្នាក់*» *និង*«*ធ្វើឲ្យមានវិន័យ*» *អាចផ្លាស់ប្តូរគ្នាបាន* (Kenyon 2007)។ ការ គ្រប់គ្រងថ្នាក់ជាយុទ្ធសាស្ត្ររបស់គ្រូដែលបង្កើត និងរក្សាឲ្យមានសណ្តាប់ធ្នាប់បរិយាកាសសិក្សា និងមានវិន័យ មានន័យថា គ្រូទទួលខុសត្រូវចំពោះអាកប្បកិរិយាខុសឆ្គងរបស់និស្សិតនៅក្នុងថ្នាក់រៀន។ អ្នកជំនាញការ Fred Jones បានកត់សម្គាល់ការគ្រប់គ្រងថ្នាក់រៀនពន្យល់ថា « *ថ្នាក់រៀនល្អមានតុកៅអីអង្គុយរត់*

*ត្រង់ជួរល្អគឺជាគុណតម្លៃសមរម្យសម្រាប់ការគ្រប់គ្រងថ្នាក់រៀននោះ ។ ការធ្វើឲ្យមានវិន័យល្អគឺឥតលក់ដូរ* » (Dunbar 2004)។ និស្សិតត្រូវអង្គុយតាមកន្លែងរបស់ខ្លួននិងបែរមុខត្រង់ទៅរកគ្រូ។ និស្សិតមានចលនាគ្រប់គ្រាន់ក្នុងសកម្មភាពសិក្សា។ និស្សិតអាចមើលឃើញក្តារខៀនច្បាស់ សំពត់បញ្ចាំងរូប(Screens) និងគ្រូ។ និស្សិតអាចអង្គុយនៅឆ្ងាយពីមាត់បង្អួច។ ថ្នាក់រៀនអាចរៀបចំប្រែប្រួលទៅតាមតម្រូវការនៃសកម្មភាពបង្រៀន។ ការគ្រប់គ្រងថ្នាក់គ្របដណ្តប់ទៅដោយដំណើរការលើកទឹកចិត្ត ការមានវិន័យ និងការគោរព។ គោលបំណងនៃការគ្រប់គ្រងថ្នាក់ ទី១ គឺបង្កើតនិងរក្សាបរិដ្ឋានវិជ្ជមានផលិតភាពសិក្សា ទី២ គឺគាំទ្រនិងជំរុញឲ្យមានសុវត្ថិភាពក្នុងថ្នាក់ (Kenyon 2007)។

3) វិធីបង្រៀនៈ ការបង្រៀន គឺជាសិល្បៈនៃការសម្តែងចំណេះរបស់គ្រូទៅកាន់អ្នកសិក្សាជាពិសេសមានសិស្ស និងនិស្សិត។ ការបង្រៀនមានការទទួលខុសត្រូវច្រើនជាងអាជីពផ្សេងទៀត មានដូចជាការទទួលខុសត្រូវសង្គម បណ្តុះបណ្តាលគំនិតឲ្យចេះគិតចេះបង្កើតសំណួរ បង្រៀនស្រាវជ្រាវរកបុព្វហេតុ ឲ្យចេះស្វែងរក។ ការបង្រៀននាបច្ចុប្បន្នមាននិន្នាការទៅរកការបង្រៀនតាមបច្ចេកទេសគ្រូមជ្ឈមណ្ឌល(The teacher center learning) និង សិស្សមជ្ឈមណ្ឌល (The student center learning)។ តាមការបកស្រាយរបស់លោក Kember ឲ្យដឹងថា *ការបង្រៀនតាមវិធីគ្រូមជ្ឈមណ្ឌលតម្រង់មាតិកាទៅរកទស្សនៈ ឬដំណើរយល់ឃើញ និងបង្រៀនតាមវិធីសិស្សមជ្ឈមណ្ឌលតម្រង់ទៅរកទស្សនៈទាន ឬការយល់ឃើញនូវគំនិតដំបូង* (Geraldine O'Neill and Tim McMahon 2005)។ ទោះយ៉ាងណាក្តី វិធីបង្រៀនមានការប្រែប្រួលទៅតាមគ្រូម្នាក់ៗ និងមានការពាក់ព័ន្ធជាមួយសមត្ថភាពគ្រូបង្រៀនផងដែរ។ វិធីបង្រៀនមានដូចជា *បង្រៀនមេរៀនសុទ្ធ បង្រៀនមេរៀនខ្លះ/ពិភាក្សាខ្លះ Jigsaw method បង្រៀនមេរៀនតាមបែបករណីសិក្សា វិធីបង្រៀនជា(តាមរបៀប)គម្រោងក្រុមធ្វើកិច្ចការ* (Team project assignment)។ ដូច្នេះដើម្បីឲ្យបានការបង្រៀនល្អ គ្រូបង្រៀនចាំបាច់ត្រូវមានសមត្ថភាពជាកត្តាសំខាន់ក្នុងការពន្យល់ បកស្រាយទស្សនៈ ទ្រឹស្តីផ្សេងៗ និងការឆ្លើយសំណួររបស់សិស្ស។ ការមានទំនាក់ទំនងល្អជាមួយសិស្សដើម្បីដឹងពីកិច្ចការរៀនសូត្ររបស់ពួកគាត់ ពីស្ថានភាពដទៃទៀតដែលទាក់ទងនឹងការសិក្សាក៏ជាជំនាញសំខាន់របស់គ្រូ។ គ្រូគប្បីចេះបង្ហាញវិធីទាញយកផលប្រយោជន៍ពីការប្រើប្រាស់ឧបករណ៍សិក្សាពីជំនាញដែលគ្រូបានបង្រៀន និងផ្តល់ការគោរពចំពោះសិស្សដែលមកសិក្សា។ ការ

បង្រៀនឲ្យមានគុណភាពសង្កត់ធ្ងន់លើកត្តាបួនយ៉ាងគឺ« *សមត្ថភាព ជំនាញទំនាក់ទំនង ផ្តល់អត្ថប្រយោជន៍ និងមានសេចក្តីគោរពចំពោះសិស្ស* » (Brain 2016) ដែលនេះជាគំនិតសំខាន់មួយ គ្រូបង្រៀនគួរត្រិះរិះពិចារណា។

4) **គ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល:** នៅក្នុងដំណើរការបង្រៀន គ្រូតែងតែមានវិធីបង្រៀនប្លែកៗ ក្នុងគោលបំណងយ៉ាងណាឲ្យការបង្រៀននោះមានការចាប់អារម្មណ៍និងមានការចូលរួមពីសិស្សដើម្បីឲ្យឆាប់ទទួលបានចំណេះដឹងនិងលទ្ធផលសិក្សាទៅតាមការរំពឹងទុក។ គរុកោសល្យនាបច្ចុប្បន្ន ការបង្រៀនមាននិន្នាការពីការបង្រៀនតាមវិធីគ្រូមជ្ឈមណ្ឌលទៅសិស្សមជ្ឈមណ្ឌល។ យោងតាមអត្ថបទបោះពុម្ពផ្សាយបញ្ហាប្រឈមគ្រូមជ្ឈមណ្ឌលនិងសិស្សមជ្ឈមណ្ឌល[2]បានបង្ហាញខាងក្រោម៖

- **គ្រូមជ្ឈមណ្ឌល:** ការបង្រៀនតាមវិធីគ្រូមជ្ឈមណ្ឌល និស្សិតបានដាក់ការពិភាក្សាលើគ្រូ។ គ្រូពិភាក្សា ខណៈពេលដែលនិស្សិតស្តាប់គ្រូពន្យល់។ នៅក្នុងថេរៈវេលានៃការបង្រៀន និស្សិតរៀនតែឯង និងកិច្ចសហការជាមួយគ្រូមានការថយចុះ។ វិធីបង្រៀនតាមបែបគ្រូមជ្ឈមណ្ឌលមានការយល់ស្របខ្លះ មិនយល់ស្របខ្លះ។ ចំនុចយល់ស្របមានដូចជាថ្នាក់រៀនមានរបៀបរៀបរយល្អ សិស្សស្ងាត់មាត់ និងគ្រូគ្រប់គ្រងពេញទាំងថ្នាក់រៀននិងសកម្មភាពបង្រៀន។ និស្សិតរៀនដោយខ្លួនឯង ការសិក្សារបស់ពួកគេគឺឯករាជ្យនិងបង្កើតការសម្រេចចិត្តខ្លួនឯង។ ចំនុចមិនយល់ស្របមានដូចជានៅពេលរៀនដោយខ្លួនឯង និស្សិតមិនទៅសហការជាមួយនិស្សិតដទៃទៀត និងជំនាញទំនាក់ទំនងប្រហែលជាបរាជ័យ។ និស្សិតមានការធុញ ចិត្តរវើរវាយ និងភាពពិតប្រហែលជាបាត់បង់សារៈសំខាន់ខ្លះ។ វិធីបង្រៀនគ្រូមជ្ឈមណ្ឌលមិនសូវអនុញ្ញាតឲ្យនិស្សិតបញ្ចេញយោបល់ សួរសំណួរ និងនិស្សិតរៀនដោយខ្លួនឯង។
- **សិស្សមជ្ឈមណ្ឌល:** នៅពេលថ្នាក់រៀនប្រតិបត្តិការជាមួយវិធីបង្រៀនសិស្សមជ្ឈមណ្ឌល សិស្សនិងគ្រូចែករំលែកការយកចិត្តទុកដាក់គ្នាទៅវិញទៅមក។ ជំនួសការស្តាប់គ្រូពន្យល់ទាំងស្រុង និស្សិតនិងគ្រូធ្វើការរួមគ្នាដើម្បីបង្កើតឲ្យមានគុណភាពសិក្សា។ ក្រុមសិក្សាត្រូវបានលើកទឹកចិត្ត និស្សិតសិក្សាត្រូវធ្វើការរួមគ្នា និងទាក់ទង

[2] (Teacher-Centered vs Student-centered Education 2012)

ជាមួយក្រុមសិក្សាផ្សេងទៀត។ វិធីបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌលមានការយល់ស្របខ្លះ មិនយល់ស្របខ្លះ។ ការយល់ស្របមានដូចជា ការសិក្សានិស្សិតមានសារៈសំខាន់ជាពិសេសការធ្វើការងាររួមគ្នាតាមក្រុមជំនាញ និស្សិតរៀនផ្ទាល់ជាមួយការសិក្សារបស់ពួកគេ មានសំណួរច្រើន និងធ្វើកិច្ចការយ៉ាងឯករាជ្យ។ និស្សិតមានសារៈប្រយោជន៍បន្ថែមទៀតនៅក្នុងសកម្មភាពសិក្សា នៅពេលពួកគេចូលរួមគ្នាជាមួយអ្នកផ្សេងទៀតនិងការមានចំណែកក្នុងសកម្មភាពសិក្សានានា។ ចំនុចមិនយល់ស្របមានដូចជា និស្សិតជជែកគ្នា ជាញឹកញាប់ថ្នាក់រៀនមានសកម្មភាពគ្រប់យ៉ាង មានសំឡេងអ៊ូរអរនិងច្របូកច្របល់។ គ្រូត្រូវព្យាយាមគ្រប់គ្រងគ្រប់សកម្មភាពសិស្សភ្លាមៗ។ ត្រូវចាត់ចែងក្រុមនិស្សិតដោយដាក់កិច្ចការផ្សេងៗគ្នាតាមលំដាប់លំដោយទៅ តាមផែនការបង្រៀន។ គ្រូមិនបង្រៀនទៅកាន់និស្សិតទាំងអស់ភ្លាមៗ និស្សិតខ្លះប្រហែលបាត់បង់សារៈសំខាន់ និស្សិតខ្លះចូលចិត្តរៀនម្នាក់ឯង ដូច្នេះក្រុមសិក្សាត្រឡប់ទៅជាមានបញ្ហា។

ទោះនៅក្នុងពេលថ្មីៗ គ្រូភាគច្រើនចូលចិត្តបង្រៀនតាមវិធីសិស្សមជ្ឈមណ្ឌលក្តី តែនៅមានសិស្សមួយចំនួនពេញចិត្តនឹងការបង្រៀនតាមវិធីគ្រូមជ្ឈមណ្ឌល ក៏មានប្រសិទ្ធភាពច្រើនដែរ។ មានករណីសិក្សាជាច្រើនថាក្នុងការបំពេញសេចក្តីត្រូវការនៃការសិក្សារបស់និស្សិត ជាការប្រសើរគ្រូបង្រៀនគួរផ្សំវិធីទាំងពីរនេះនៅក្នុងសកម្មភាពបង្រៀនដើម្បីបំពេញតម្រូវការផ្សេងៗគ្នានៃការសិក្សារបស់និស្សិត និងសម្រេចបានលទ្ធផលសិក្សាល្អ។

5) ការរៀបចំមេរៀនលម្អិតសម្រាប់បង្រៀនៈ ដើម្បីបង្រៀនឲ្យបានល្អ គ្រូចំណាយពេលច្រើននៅខាងក្រៅសាលាលើកិច្ចតែងការបង្រៀន។ តាមធម្មតាគ្រូចំណាយច្រើនម៉ោងទោះក្នុងថ្ងៃសម្រាកយ៉ាងណាក្តី ដើម្បីរៀបចំមេរៀនលម្អិតសម្រាប់បង្រៀន រៀបចំផែនការសកម្មភាព និងកំណត់ភាពកណ្តាលក្នុងការតាក់តែងមេរៀនដើម្បីឲ្យសិស្សមានឱកាសសិក្សាបានជាអតិបរមា។ ម្យ៉ាងទៀត ការរៀបចំកិច្ចតែងការបង្រៀន គឺជាផែនទីបង្ហាញផ្លូវរបស់គ្រូបង្រៀនសម្រាប់បំពេញសេចក្តីត្រូវការអ្វីដែលនិស្សិតត្រូវសិក្សា និង បង្រៀនរបៀបណាឲ្យមានប្រសិទ្ធភាពនៃថេរវេលាក្នុងពេលនៅក្នុងថ្នាក់រៀន (Milkova 2016)។ មុននឹងរៀបចំប្លង់មេរៀន ជាដំបូងគ្រូត្រូវកំណត់នូវកម្មវត្ថុនៃការសិក្សារបស់មេរៀនសម្រាប់បង្រៀនសិស្សជុំគ្នានៅក្នុងថ្នាក់។ ភាពជោគជ័យនៃការរៀបចំប្លង់មេរៀនអាស្រ័យដោយភាព

ប៉ិនប្រសប់ និងការបញ្ចូលលាយគ្នាជាមួយធាតុផ្សំបី គឺកម្មវត្ថុសម្រាប់និស្សិតសិក្សា សកម្មភាពបង្រៀននិងសិក្សា និងយុទ្ធសាស្ត្រសម្រាប់ត្រួតពិនិត្យការយល់ខ្លឹមសារមេរៀនរបស់និស្សិត។

6) បរិស្ថានថ្នាក់រៀនៈ ការរៀបចំថ្នាក់រៀនឲ្យល្អជាតម្រូវការចាំបាច់សម្រាប់គាំទ្រដល់ការបង្រៀន និងការរៀនរបស់និស្សិត។ ជាចិត្តសាស្ត្រ បរិស្ថានសម្រាប់ថ្នាក់រៀនអាចជំរុញបរិយាកាសសិក្សា និងការពារបញ្ហាដែលអាចកើតមានឡើងជាយថាហេតុដល់និស្សិត។ ការចាត់ចែងរូបវន្តសម្រាប់បន្ទប់សិក្សាអាចមានឥទ្ធពលអាកប្បកិរិយាប្រែប្រួលទាំងពីរផ្នែក ទាំងគ្រូ និងសិស្ស និងជម្រុញលទ្ធផលសិក្សារបស់និស្សិត (Aivazis 2005)។ លំហារនៃទ្រង់ទ្រាយបន្ទប់សិក្សាអាស្រ័យទៅនឹងកន្លែងអង្គុយរបស់និស្សិតដូចម្តេច កន្លែងណាដែលនិស្សិតអាចទាក់ទងទៅនិស្សិតម្នាក់ទៀត សមាជិកក្នុងថ្នាក់រៀនចល័តខ្វែងគ្នាដូចម្តេច បរិយាកាសក្នុងថ្នាក់រៀន និងកត្តាផ្សេងទៀត។ ថ្នាក់រៀនអនុញ្ញាតឲ្យគ្រូសម្តែងការបង្រៀន ការជួបជុំ និងតម្រូវការចាំបាច់ផ្សេងទៀតដល់និស្សិត។ ម្យ៉ាងទៀត ទិដ្ឋភាព និងការរួមបញ្ចូលគ្នានៃបរិស្ថានថ្នាក់រៀនអាចប្រែប្រួលច្រើនទៅតាមលទ្ធផលសិក្សាវិជ្ជមាន និងអវិជ្ជមានរបស់និស្សិត។ ទាក់ទងនឹងបរិស្ថានរូបវន្តតម្រូវឲ្យធ្វើការត្រួតពិនិត្យល្អិតល្អន់ ទិដ្ឋភាពមានដូចជា ការរៀបចំសមាសភាពផ្សំក្នុងថ្នាក់រៀន ទំហំថ្នាក់ (សិស្សច្រើន ឬតិច) និងការគ្រប់គ្រងថ្នាក់។ ចំណែកបរិយាកាសថ្នាក់រៀនមានការពាក់ព័ន្ធជាមួយទំនាក់ទំនងរវាងនិស្សិតម្នាក់ទៅនិស្សិតម្នាក់ផ្សេងទៀត ការបង្រៀននិងការសម្តែងនៅក្នុងការសិក្សាដែលជាចំណុចសំខាន់នៅក្នុងថ្នាក់រៀន។ បន្ថែមពីនេះ កត្តាបរិស្ថានចិត្តសាស្ត្រដើរតួនាទីសំខាន់បង្កើតទំនាក់ទំនងល្អ ជិតស្និតរវាងសិស្សនិងគ្រូ ការផ្តោតសំខាន់លើអត្រានៃការចូលរួមរបស់និស្សិត ការគាំទ្ររបស់គ្រូ និងការទាក់ទងគ្នាសម្រាប់គោលបំណងនៃការសិក្សារបស់និស្សិត (Angela Miller & Kathryn Cunningham 2003)។

7) សារៈសំខាន់វិធីបង្រៀនៈ គ្រូម្នាក់ៗមានវិធីបង្រៀនផ្សេងៗពីគ្នាទៅតាមទេពកោល្យទៅតាមស្ថានភាពទីកន្លង ជាពិសេសប្រែប្រួលទៅតាមឥរិយាបថ និងសមត្ថភាពសិស្ស។ ខាងក្រោមនេះជាវិធីបង្រៀនដែលគ្រូតែងតែយកមកអនុវត្តការបង្រៀនដើម្បីផ្ទេរចំណេះវិជ្ជាៈ

- **បង្រៀនមេរៀនសុទ្ធ**គឺគ្រូមានឥទ្ធិពលទីមួយនៃការងារបង្រៀនក្នុងថ្នាក់ មានន័យថាគ្រូយកចិត្តទុកដាក់បង្រៀនមេរៀនយ៉ាងលើសលុប ចំណែកសកម្មភាពសិស្សក្នុង

ថ្នាក់គឺថាំការទទួលយកចំណេះដឹង។ វិធីបង្រៀនមានចំនុចអវិជ្ជមានខ្លះដូចជាការថយចុះកម្រិតយកចិត្តទុកដាក់ក្នុងការសិក្សា ការទុកពេលវេលាឲ្យចេះតែកន្លងផុតទៅដោយសារតែការធុញជាដើម។

- **បង្រៀនខ្លះ/ ពិភាក្សាខ្លះ**គឺសិស្សមានភាពជាចម្បង សកម្មក្នុងការសិក្សា មានកិច្ចការច្រើនទាក់ទងនឹងការសិក្សាស្រាវជ្រាវ ចំណែកគ្រូមានតួនាទីជាអ្នកចង្អុលផ្លូវនៃការសិក្សារបស់និស្សិត ឬផ្តល់ប្រឹក្សាជាគំនិតតម្រង់ទិសដើម្បីជម្រុញសកម្មភាពសិក្សាឲ្យកាន់តែមានប្រសិទ្ធភាពឡើង។
- Jigsaw method គឺជាវិធីដែលមានផលល្អដើម្បីបង្កើនចំណេះតាមរយៈឧបករណ៍សិក្សាជាក់លាក់នៅក្នុងការសហការរបៀបរៀន។ ដំណើរការវិធីបង្រៀនJigsawលើកទឹកចិត្តការស្តាប់ ការចូលរួម និងការយល់ចិត្តដោយផ្តល់ឲ្យសមាជិករបស់ក្រុមនីមួយៗមានតួនាទីជាផ្នែកសំខាន់នៅក្នុងសកម្មភាពរៀនសូត្រ។ សមាជិកក្រុមនីមួយៗធ្វើការរួមគ្នាដូចៗគ្នានៅក្នុងក្រុមដើម្បីសម្រេចគោលដៅរួម, ម្នាក់ៗមានការទាក់ទងគ្នាជាមួយសមាជិកក្រុមទាំងមូល។ គ្មាននិស្សិតណាម្នាក់អាចបំពេញការងារបានល្អទេ លុះត្រាតែទាំងអស់គ្នាធ្វើការរួមគ្នាបានល្អនៅក្នុងក្រុម។
- បង្រៀនតាមបែបករណីសិក្សា គឺបង្ហាញដល់និស្សិតនូវបញ្ហាជាក់ស្តែងដែលកើតមានដល់ការរស់នៅនិងជួយឲ្យការងារអនុវត្តអាចធ្វើទៅបានដែលនិស្សិតបានសិក្សានៅក្នុងថ្នាក់ជាមួយករណីសិក្សានេះ។ ករណីសិក្សាជម្រុញទឹកចិត្តនិស្សិតឲ្យអភិវឌ្ឍជំនាញដោះស្រាយបញ្ហាបានសមហេតុសមផល និងប្រើប្រាស់នៅក្នុងក្រុមនាំមុខ ឬនៅក្នុងសហប្រតិបត្តិការក្រុមជំនាញ។
- វិធីបង្រៀនតាមរបៀបក្រុមគម្រោងធ្វើ*assignment* (Team project assignment) គឺជាទស្សនៈនៃការសន្ទនាផ្លាស់ប្តូរគំនិតអំពីការសិក្សាតែម្យ៉ាងគត់នៅក្នុងទំនាក់ទំនង ទ្វេភាគីគ្រូនិងសិស្ស ដូចជាកំណត់ឲ្យបានឆាប់រហ័យ ពិពណ៌នានៃជម្រើសកិច្ចការទៅនិស្សិតដែលអាចធ្វើបាន(assignment)ជាមួយលក្ខណៈវិនិច្ឆ័យអ្វីខ្លះ និង ប្រើប្រាស់ស្តង់ដាបែបណា ត្រូវធ្វើការវិនិច្ឆ័យដូចម្តេច និងនរណាជាអ្នកធ្វើការវាយតម្លៃ។ ខាងក្រោមនេះជាទម្រង់នៃការរៀបចំវិធីបង្រៀនតាមរបៀបក្រុមគម្រោងធ្វើ assignment ដែលគ្រូដាក់កិច្ចការឲ្យនិស្សិតចូលរួមក្នុងដំណើរការធ្វើកិច្ចការ ៖

| | |
|---|---|
| ការចូលរួមរបស់និស្សិតនៅដំណាក់កាលដែលកិច្ចការរៀបចំជាសំណុំ | • ជ្រើសរើសការវាយតម្លៃកិច្ចការ<br>• កំណត់ការវាយតម្លៃកិច្ចការ<br>• ពិភាក្សាការវាយតម្លៃលក្ខណៈវិនិច្ឆ័យ<br>• កំណត់ការវាយតម្លៃលក្ខណៈវិនិច្ឆ័យ |

| | |
|---|---|
| ការចូលរួមរបស់និស្សិតនៅដំណាក់កាលបន្ទាប់ពីកិច្ចការបានរៀបចំពេញលេញ | • ការផ្តល់យោបល់ត្រូវធ្វើការវាយតម្លៃខ្លួនឯង<br>• ធ្វើការត្រួតពិនិត្យលើការវាយតម្លៃនៃការផ្តល់យោបល់គ្រូឡប់<br>• ផ្តល់យោបល់ការវាយតម្លៃត្រឡប់ដោយខ្លួនឯង (*ដាក់ពិន្ទុ*)<br>• ព្រមព្រៀងវាយតម្លៃដោយខ្លួនឯង(*ដាក់ពិន្ទុ*)<br>• កំណត់ការវាយតម្លៃដោយខ្លួនឯង(*ដាក់ពិន្ទុ*)<br>• កំណត់ការត្រួតពិនិត្យវាយតម្លៃដោយខ្លួនឯង(*ដាក់ពិន្ទុ*) |

( Source: Student centered learning: what does it mean for students and lecturers ? 2005, p32 )

ការបង្រៀនអាចធ្វើការសំយោគជាបីដំណាក់ (Steve Bissonnette, Carl Bouchard 2017)៖ ដំណាក់កាលទី១ ក្នុងខណៈនៃការធ្វើបទបង្ហាញនិងការស្រាយបំភ្លឺ អ្នកបង្រៀនត្រូវខិតខំសម្តែងឲ្យឃើញនូវភាពជាក់លាក់គ្រប់ហេតុផល ដែលមានស្រាប់នៅក្នុងមេរៀនដែលបានត្រៀមទុកនិងទាំងមិនបានត្រៀមទុក ដោយបង្រៀនឲ្យមានគំនិតឆ្លល់ជាមួយសព្វនាម *អ្វី ហេតុអ្វី ដូចម្តេច នៅពេលណានិងធ្វើនៅកន្លែងណា* ។ ដំណាក់កាលទី២ អ្នកបង្រៀន*ត្រូវយកពេលវេលាដើម្បីផ្ទៀងផ្ទាត់អ្វីដែលនិស្សិតបានយល់ពីការធ្វើបទបង្ហាញ ឬការស្រាយបំភ្លឺដែលគ្រូបានបង្រៀន* ផ្តល់ឲ្យកិច្ចការអ្វីដែលមើលឃើញពិត ធ្វើកិច្ចការជាក្រុម កម្រិតកិច្ចការក្រុមគឺប្រហាក់ប្រហែលគ្នា ត្រូវធ្វើឲ្យបានសម្រេចទៅតាមគំរូដែលបានណែនាំកំណត់ឲ្យធ្វើ។ ដំណាក់កាលទី៣ សិស្សម្នាក់ៗ*ត្រូវសិក្សាឡើងវិញដោយខ្លួនឯងនូវអ្វីដែលបានយល់*ពីកិច្ចការដែលបានធ្វើចប់សព្វគ្រប់ហើយ និងការអវត្តន៍នៅក្នុងក្រុម នៅក្នុងខណៈដឹកនាំការអនុវត្តន៍ នៅក្នុង*ចំណោទបញ្ហាមួយចំនួន ឬសំណួរមួយចំនួន*។

សរុបសេចក្តីមកការបង្រៀនមានកម្រិតមូលដ្ឋានបី៖ កម្រិទី១ ការបង្រៀនជាក់លាក់តាមការគ្រោងទុក និងការវាយតម្លៃទៀងទាត់ កម្រិទី២ ផ្តល់ឱកាសបង្រៀនបន្ថែមជំនាញ រៀបចំក្រុមសិក្សាតូចៗ(២-៥នាក់)ដែលក្រុមនីមួយៗមានកិច្ចការធ្វើផ្សេងគ្នា ក្នុងកម្រិតប្រហែលគ្នាអន្តរាគមន៍ឲ្យបានសម្រេចលើកិច្ចការជាក់លាក់ដែលបានដាក់ឲ្យ លម្អិតនិងតម្រង់ទិសដៅផ្សេងៗគ្នានៃនិស្សិតម្នាក់ៗ ធ្វើការវាយតម្លៃទៀងទាត់។ កម្រិទី៣ ផ្តល់ឱកាសបង្រៀនបន្ថែមជំនាញ ចេញខ្លួនជួយដោយចេតនាដោយខ្លួនឯងនិងនៅចំពោះមុខកិច្ចការជាក់លាក់បន្ទាប់ពីនិស្សិតមានតម្រូវការចំពោះមុខងារពិសេសរបស់ពួកគាត់ និងធ្វើការវាយតម្លៃទៀងទាត់។

## III. វិធីសាស្ត្រស្រាវជ្រាវ

### 1) ការកំណត់វិធីសាស្ត្រ

ការស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រចំរុះ មានការវិភាគតាមបែបគុណវិស័យខ្លះ និងតាមវិធីបរិមាណវិស័យខ្លះ។ ឧបករណ៍វិភាគប្រើ SPSS Program។ ទិន្នន័យសម្រាប់ធ្វើការវិភាគគឺទិន្នន័យទី១(Primary data)។ ប្រើប្រាស់កម្រងសំណួរចំនួន១៥សំណួរដែលជាសំណួរបិទ និងមានការបញ្ជាក់ពីការវាស់សេចក្តីពេញចិត្ត(មើលឧបសម្ព័ន្ធទី១) សម្រាប់ឲ្យនិស្សិតឆ្លើយ និងមានសំណួរបើកចំនួន ៣សំណួរបន្ថែម។ រយៈពេលនៃការប្រមូលទិន្នន័យនៅចន្លោះខែមេសា និងខែឧសភា ឆ្នាំ២០១៧។ ដំណើរការប្រមូលទិន្នន័យធ្វើនៅក្នុងបរិវេណ **សភនវស** លើចំនួននិស្សិត ២០០នាក់ ដោយចៃដន្យ(random) ។ ក្នុងនោះមានបុរសមាន ១០៥នាក់ ស្មើនឹង ៥២,៥% និងនារីមាន ៩៥នាក់ ស្មើនឹង ៤៧,៥%។ យកមុខវិជ្ជា ១៦ មកធ្វើការស្រាវជ្រាវស្វែងរកវិធីសាស្ត្របង្រៀនណាដែលនិស្សិតមានសេចក្តីពេញចិត្តជាងគេ និងអាចងាយយល់ ជាជាងអនុវត្តវិធីបង្រៀនណាមួយដែលនិស្សិតមានការធុញ ពិបាកយល់។ ក្នុងករណីដែលការស្រាវជ្រាវនេះទទួលបានលទ្ធផលវិធីបង្រៀនណាមួយ ដែលនិស្សិតពេញចិត្តហើយ អ្នកបង្រៀនអាចយកវិធីបង្រៀននោះទៅសាកល្បងជាមួយនិស្សិត និងធ្វើការកត់សម្គាល់លើលទ្ធផលរំពឹងទុកថាតើវានឹងមានការប្រែប្រួល ឬវិវឌ្ឍយ៉ាងណាទៀត។

ក្នុងការកំណត់លទ្ធផលរំពឹងទុកនៃការស្រាវជ្រាវលើវិធីបង្រៀននេះ គឺបានកំណត់យកវិធីសាស្ត្រពីរ៖ វិធីទី១ **ប្រៀបធៀបពិន្ទុមធ្យមនៃវិធីបង្រៀនទាំងប្រាំ** និងវិធីទី២ **យកវិធីបង្រៀនណាមួយធ្វើជាគោលធៀបដើម្បីស្វែងរកវិធីបង្រៀនណា ដែលមានអនុបាត (ratio) ខ្ពស់ជាងគេ** ដែលអាចកំណត់ថាជាវិធីបង្រៀនមួយមានប្រសិទ្ធភាពនៅថ្នាក់ឧត្តមសិក្សា។

### 2) ការបង្ហាញលទ្ធផលបន្តបន្ទាប់នៃសំណួរស្រាវជ្រាវនីមួយៗ៖

**សំណួរទី៥** កម្រិតយល់ស្របជាមួយមុខវិជ្ជាដែលកំពុងសិក្សា

- មុខវិជ្ជាដែលកំពុងសិក្សាមានសារៈសំខាន់ខ្លាំង និស្សិតបានបង្ហាញកម្រិតយល់ស្របដូចបង្ហាញលើក្រាភិកខាងក្រោមនេះ ៖

**តារាងទី១ មុខវិជ្ជាដែលកំពុងសិក្សាមានសារៈសំខាន់**




| | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|
| ភាគរយ | 1.5 | 11.0 | 55.5 | 32.0 |
| ចំនួន | 3 | 22 | 111 | 64 |

មុខវិជ្ជាដែលមាននៅក្នុងកម្មវិធិសិក្សាទាំងផ្នែកច្បាប់និងផ្នែកសេដ្ឋកិច្ចនិស្សិតបានផ្ដល់សារសំខាន់កម្រិតយល់ស្របមាន ៥៥,៥% កម្រិតយល់ស្របទាំងស្រុង ៣២,០% ករណីយល់ស្របបង្គួរមាន ១១,០% និងយល់ស្របតិចតួចមាន ១,៥%។

- ការបានរៀនលើមុខវិជ្ជាដែលកំពុងសិក្សាយ៉ាងច្រើនម៉ោង និស្សិតបានបង្ហាញកម្រិតយល់ស្របលើក្រាភិកខាងក្រោមនេះ៖

**តារាងទី២ សិក្សាច្រើនម៉ោងលើមុខវិជ្ជានេះ**




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 2.0 | 15.5 | 39.0 | 36.0 | 7.5 |
| ចំនួន | 4 | 31 | 78 | 72 | 15 |

ការបានរៀនលើមុខវិជ្ជាដែលកំពុងសិក្សាច្រើនម៉ោង កម្រិតយល់ស្របមាន ៣៦,០% កម្រិតយល់ស្របទាំងស្រុងមាន ៧,៥% ករណីដែលយល់ស្របបង្គួរមាន ៣៩,០% យល់ស្របតិចតួចមាន១៥,៥% និងមិនយល់ស្របមាន ២,០%។

- ខ្លឹមសារដែលមានក្នុងមុខវិជ្ជាដែលកំពុងរៀននេះមានសារៈសំខាន់ខ្លាំង និស្សិតបានបង្ហាញកម្រិតយល់ស្របនៅលើក្រាភិកខាងក្រោមនេះ ៖

**តារាងទី៣ ខ្លឹមសារដែលមានក្នុងមុខវិជ្ជានេះមានសារៈសំខាន់ខ្លាំង**




| | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|
| ភាគរយ | 1.5 | 20.1 | 53.3 | 25.1 |
| ចំនួន | 3 | 40 | 106 | 50 |

ខ្លឹមសារដែលមាននៅក្នុងមេរៀនមានសារៈសំខាន់ខ្លាំង កម្រិតយល់ស្របមាន ៥៣,៣% កម្រិតយល់ស្របទាំងស្រុងមាន ២៥,១% ករណីកម្រិតយល់ស្របបង្គួរមាន ២០,១% និងយល់ស្របតិចតួចមាន ១,៥%។

- បើប្រៀបធៀបនឹងមុខវិជ្ជាផ្សេង មុខវិជ្ជាដែលកំពុងសិក្សាមានភាពងាយស្រួលដល់ខ្ញុំ និស្សិតបានបង្ហាញកម្រិតយល់ស្របនៅលើក្រាភិកខាងក្រោមនេះ៖

**តារាងទី៤ មុខវិជ្ជានេះងាយស្រួលជាងមុខវិជ្ជាផ្សេង**




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 6.5 | 14.6 | 41.2 | 31.2 | 6.5 |
| ចំនួន | 13 | 29 | 82 | 62 | 13 |

មុខវិជ្ជាកំពុងរៀនមានភាពងាយស្រួលជាងមុខវិជ្ជាផ្សេង កម្រិតយល់ស្របមាន ៣១,២% កម្រិតយល់ស្របទាំងស្រុងមាន ៦,៥% ករណីយល់ស្របបង្គួរមាន ៤១,២% យល់ស្របតិចតួចមាន ១៤,៦% និងមិនយល់ស្របមាន ៦,៥%។

- ជារួម ការយល់ថា ការដាក់ Assignment និងកិច្ចការផ្សេងៗនៃមុខវិជ្ជាដែលកំពុងសិក្សាគឺមានប្រយោជន៍ និស្សិតបង្ហាញកម្រិតយល់ស្របលើក្រាភិកខាងក្រោម ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | .5 | .5 | 10.5 | 46.5 | 42.0 |
| ចំនួន | 1 | 1 | 21 | 93 | 84 |

ការដាក់ Assignment និងដាក់កិច្ចការផ្សេងៗនៃមុខវិជ្ជាដែលកំពុងសិក្សាគឺមានប្រយោជន៍ កម្រិតយល់ស្របមាន ៤៦,៥% កម្រិតយល់ស្របទាំងស្រុងមាន ៤២,០% ករណីយល់ស្របបង្គួរមាន ១០,៥% យល់ស្របតិចតួចមាន ០,៥% និងមិនយល់ស្រប មាន ០,៥%។

**សំណួរទី៦** មេរៀនទី១នៃមុខវិជ្ជាដែលកំពុងសិក្សា មាតិកានៃមេរៀននេះបានបង្ហាញពីទម្រង់បង្រៀនសុទ្ធ(គ្មានការពិភាក្សាក្រុម ឬសកម្មភាពផ្សេងៗក្នុងពេលកំពុងរៀន) និស្សិតបានបង្ហាញកម្រិតយល់ស្របលើក្រាភិកជាបន្តបន្ទាប់ខាងក្រោមនេះ។

- ករណីបង្រៀនសុទ្ធតែមេរៀនជាច្រើនម៉ោង និស្សិតបានបង្ហាញកម្រិតយល់ស្របនៅលើក្រាភិកខាងក្រោមនេះ ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 10.1 | 23.1 | 35.7 | 27.6 | 3.5 |
| ចំនួន | 20 | 46 | 71 | 55 | 7 |

បានរៀនច្រើនម៉ោងដែលបង្រៀនសុទ្ធតែមេរៀន កម្រិតយល់ស្របមាន ២៧,៦% កម្រិតយល់ស្របទាំងស្រុងមាន ៣,៥% ករណីកម្រិតយល់ស្របបង្គួរមាន ៣៥,៧% យល់ស្របតិចតួចមាន ២៣,១% និងមិនយល់ស្របមាន ១០,១%។

- ចង់ឲ្យមានការអនុវត្តខ្លះនៅក្នុងទម្រង់នៃការបង្រៀនតែមេរៀនសុទ្ធ និស្សិតផ្ដល់កម្រិតនៃការយល់ស្របនៅលើក្រាភិកខាងក្រោមនេះ ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 3.0 | 8.0 | 15.0 | 51.0 | 23.0 |
| ចំនួន | 6 | 16 | 30 | 102 | 46 |

ការចង់ឲ្យមានការអនុវត្តខ្លះនៅក្នុងវិធីបង្រៀនសុទ្ធតែមេរៀន និស្សិតមានការយល់ស្រប ៥១,០% និងយល់ស្របទាំងស្រុង ២៣,០% ករណីយល់ស្របបង្គួរមាន ១៥,៥% យល់ស្រប

តិចតួចមាន ៨,០% និងមិនយល់ស្របមាន ៣,០%។ ជារួមនិស្សិតត្រូវការវិធីបង្រៀនដែលមានការអនុវត្តប្រមាណ ៧៩,០% ដើម្បីស្វែងយល់លើមុខវិជ្ជដែលកំពុងសិក្សា។

- ការឈានទៅរកការប្រើប្រាស់ឧបករណ៍សិក្សាក្នុងវិធីសាស្ត្របង្រៀនមេរៀនសុទ្ធ និស្សិតផ្តល់កម្រិតយល់ស្របនៅលើក្រាភិកខាងក្រោមនេះ ៖

**តារាងទី៨ ការប្រើប្រាស់ឧបករណ៍នៅក្នុងការបង្រៀនមេរៀនសុទ្ធ**




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 11.0 | 17.0 | 25.0 | 37.0 | 10.0 |
| ចំនួន | 22 | 34 | 50 | 74 | 20 |

និស្សិតចង់បានការប្រើប្រាស់ឧបករណ៍សិក្សានៅក្នុងពេលបង្រៀន កម្រិតយល់ស្របមាន ៣៧,០% និងយល់ស្របទាំងស្រុងមាន ១០,០% ករណីយល់ស្របបង្គួរមាន២៥,០% យល់ស្របតិចតួចមាន ១៧,០% និងមិនយល់ស្របមាន ១១,០%។ ជារួមនិស្សិតចង់បានការបង្រៀនត្រូវមានឧបករណ៍សិក្សាដើម្បីជំនួយដល់ការរៀនអាចឆាប់យល់ គឺមានកម្រិតយល់ស្រប ៤៧,០%។

**សំណួរទី៧** មេរៀនទី២នៃមុខវិជ្ជា: មាតិកាមេរៀនបានបង្ហាញពីទម្រង់ជាការបង្រៀនមេរៀនខ្លះ/ ទម្រង់ពិភាក្សាខ្លះ(ការបង្រៀនច្រើន និងផ្តល់ពេលខ្លះឲ្យពិភាក្សាជាក្រុម)។ កម្រិតនៃការយល់ស្របបង្ហាញនៅលើក្រាភិកខាងក្រោមនេះ ៖

- រៀនមេរៀនច្រើនម៉ោង/ បានពិភាក្សាផ្នែកខ្លះនៃមេរៀននេះ។ និស្សិតបានផ្តល់កម្រិតនៃការយល់ស្របលើក្រាភិកខាងក្រោម ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 3.0 | 19.5 | 41.0 | 34.5 | 2.0 |
| ចំនួន | 6 | 39 | 82 | 69 | 4 |

ការបង្រៀនមេរៀនច្រើនម៉ោង និងបានពិភាក្សាផ្នែកខ្លះនៃមេរៀន និស្សិតផ្តល់កម្រិតយល់ស្របមានចំនួន ៣៤,៥% យល់ស្របទាំងស្រុងមាន ២,០% ករណីយល់ស្របបង្គួរមាន ៤១,០% យល់ស្របតិចតួចមាន ១៩,៥% និងមិនយល់ស្របមាន ៣,០%។ ជាទូទៅនិស្សិតចង់បានការបង្រៀនមេរៀនច្រើនម៉ោង និងបានពិភាក្សាផ្នែកខ្លះនៃមេរៀនក្នុងកម្រិតយល់ស្រប ៣៦,៥%។

- ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍ខ្លះនៅក្នុងទម្រង់បង្រៀនសុទ្ធ/ មានការពិភាក្សាខ្លះ។ កម្រិតយល់ស្របនៃនិស្សិតបង្ហាញក្នុងក្រាភិកខាងក្រោម ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 1.0 | 3.5 | 13.5 | 61.5 | 20.5 |
| ចំនួន | 2 | 7 | 27 | 123 | 41 |

ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍ខ្លះក្នុងវិធីបង្រៀនសុទ្ធ / មានការពិភាក្សាខ្លះ កម្រិតយល់ស្របមាន ៦១,៥% យល់ស្របទាំងស្រុងមាន ២០,៥% ករណីយល់ស្របង្គួរមាន ១៣,៥% យល់ស្របតិចតួចមាន ៣,៥% និងមិនយល់ស្រប ១,០%។ ជារួមនិស្សិតបង្ហាញកម្រិតយល់ស្រប ៨២,០% ត្រូវការវិធីបង្រៀនដែលមានការអនុវត្តខ្លះនៃទម្រង់បង្រៀនតែមេរៀនសុទ្ធ។

- ការប្រើឧបករណ៍មានសារៈសំខាន់មានការអនុវត្តខ្លះក្នុងទម្រង់បង្រៀងសុទ្ធ និស្សិតបានផ្តល់កម្រិតយល់ស្របលើក្រាភិកខាងក្រោម ៖

**តារាងទី១១ ការប្រើឧបករណ៍មានសារៈសំខាន់មានការអនុវត្តខ្លះក្នុងទម្រង់បង្រៀងសុទ្ធ**




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | .5 | 5.0 | 14.0 | 51.5 | 29.0 |
| ចំនួន | 1 | 10 | 28 | 103 | 58 |

ការប្រើឧបករណ៍មានសារៈសំខាន់មានការអនុវត្តខ្លះក្នុងទម្រង់បង្រៀងសុទ្ធ និស្សិតយល់ស្របមានកម្រិត ៥១,៥% យល់ស្របទាំងស្រុងមាន ២៩,០% ករណីយល់ស្របបង្គួរមាន ១៤,០% យល់ស្របតិចតួចមាន ៥,០% និងមិនយល់ស្របមាន ០,៥%។ ជារួមនិស្សិតត្រូវការវិធីបង្រៀនមួយដែលមានប្រើប្រាស់ឧបករណ៍សិក្សាដើម្បីជួយការរៀនឆាប់យល់បាន។

**សំណួរទី៨** មេរៀនទី៣នៃមុខវិជ្ជាមាតិកាមេរៀនបានបង្ហាញពីទម្រង់បង្រៀនបែប Jigsaw។ កម្រិតយល់ស្របលើវិធីបង្រៀនតាមបែបJigsaw និស្សិតបង្ហាញលើក្រាភិកខាងក្រោម ៖

- បានរៀនច្រើម៉ោងតាមវិធី Jigsaw ច្រើនម៉ោងនៅក្នុងផ្នែកខ្លះក្នុងមេរៀននេះ។ និស្សិតបានបង្ហាញកម្រិតយល់ស្របលើក្រាភិកខាងក្រោម ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 14.2 | 24.6 | 41.5 | 18.0 | 1.6 |
| ចំនួន | 26 | 45 | 76 | 33 | 3 |

បានរៀនច្រើនម៉ោងតាមវិធី Jigsaw និស្សិតផ្ដល់កម្រិតយល់ស្របមាន ១៨,០% យល់ស្របទាំងស្រុងមាន ១,៦% ករណីយល់ស្របបង្គួរមាន ៤១,៥% យល់ស្របតិចតួចមាន ២៤,៦% និងមិនយល់ស្របមាន ១៤,២%។ ជារួមនិស្សិតមានការយល់ស្របលើវិធីបង្រៀនតាមបែប Jigsaw មាន ១៩,៦%។ នេះបញ្ជាក់ថា Jigsaw ជាវិធីបង្រៀនថ្មីមួយដែលនិស្សិតស្គាល់តិចតួច ឬអាចមានអ្នកបង្រៀនខ្លះពុំបានយកមកអនុវត្តដែរ។

- ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍តាមវិធីបង្រៀនJigsaw ។ និស្សិតផ្ដល់កម្រិតយល់ស្រមលើក្រាភិកខាងក្រោម ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 6.5 | 15.8 | 29.3 | 41.8 | 6.5 |
| ចំនួន | 12 | 29 | 54 | 77 | 12 |

ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍តាមវិធីបង្រៀនJigsaw និស្សិតផ្តល់កម្រិតយល់ស្របមាន ៤១,៨% យល់ស្របទាំងស្រុងមាន ៦,៥% ករណីយល់ស្របបង្គួរមាន ២៩,៣% យល់ស្របតិចតួចមាន ១៥,៨% និងមិនយល់ស្របមាន ៦,៥%។ ជារួមចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍តាមវិធីបង្រៀនJigsaw មានចំនួន ៤៨,៣% ដើម្បីឲ្យការរៀនតាមវិធីបង្រៀន Jigsaw ឆាប់យល់បាន។

- បង្រៀនតាមវិធី Jigsaw នាំឲ្យមានការប្រើប្រាស់ឧបករណ៍សិក្សា។ និស្សិតផ្តល់ការយល់ស្របលើក្រាភិកខាងក្រោម ៖

តារាងទី១៤ វិធីបង្រៀន JIGSAW ជាបធ្យោបាយល្អក្នុងការប្រើប្រាស់ឧបករណ៍សិក្សា




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 4.4 | 14.2 | 29.0 | 41.0 | 11.5 |
| ចំនួន | 8 | 26 | 53 | 75 | 21 |

ការប្រើប្រាស់ឧបករណ៍សិក្សាតាមវិធីបង្រៀន Jigsaw និស្សិតមានការយល់ស្របចំនួន ៤១,០% យល់ស្របទាំងស្រុងមាន ១១,៥% ករណីយល់ស្របបង្គួរមាន ២៩,០% យល់ស្របតិចតួចមាន ១៤,២% និងមិនយល់ស្របមាន ៤,៤%។ ជារួមនិស្សិតចង់បានការប្រើប្រាស់ឧបករណ៍សិក្សាចំនួន ៥២,៥% តាមវិធីបង្រៀន Jigsaw។

**សំណួរទី៩** មេរៀនទី៤នៃមុខវិជ្ជា: មាតិកាមេរៀនប្រើវិធីសាស្ត្របង្រៀនជាករណីសិក្សា។ និស្សិតបង្ហាញការយល់ស្របនៅលើក្រាភិកខាងក្រោម ៖

- បង្រៀនជាករណីសិក្សាច្រើនម៉ោងលើផ្នែកខ្លះនៃមេរៀន។ និស្សិតបង្ហាញការយល់ស្របនៅលើក្រាភិកខាងក្រោម ៖

**តារាងទី១៥ ផ្នែកខ្លះនៃមេរៀនមានការសិក្សាលើករណីសិក្សាច្រើនម៉ោង**




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 2.5 | 34.8 | 33.8 | 24.7 | 4.0 |
| ចំនួន | 5 | 69 | 67 | 49 | 8 |

បង្រៀនជាករណីសិក្សាច្រើនម៉ោងលើផ្នែកខ្លះនៃមេរៀន និស្សិតបង្ហាញការយល់ស្រប ចំនួន ២៤,៧% យល់ស្របទាំងស្រុងមាន ៤,០% ករណីយល់ស្របបង្គួរមាន ៣៣,៨% យល់ស្របតិចតួចមាន ៣៤,៨% និងមិនយល់ស្របមាន ២,៥%។ ជារួមនិស្សិតចង់បានការបង្រៀនជាករណីសិក្សាច្រើនម៉ោងលើផ្នែកខ្លះនៃមេរៀនចំនួន ២៨,៧% ដើម្បីជួយការសិក្សាឆាប់យល់បាន។

- ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍ក្នុងទ្រង់ទ្រាយជាករណីសិក្សា។ និស្សិតបានបង្ហាញការយល់ស្របលើក្រាភិកខាងក្រោម ៖

**តារាងទី១៦ ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តក្នុងទ្រង់ទ្រាយករណីសិក្សា**




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | .5 | 8.1 | 20.7 | 56.1 | 14.6 |
| ចំនួន | 1 | 16 | 41 | 111 | 29 |

ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍ក្នុងទ្រង់ទ្រាយជាករណីសិក្សា និស្សិតផ្តល់កម្រិតយល់ស្របមាន ៥៦,១% យល់ស្របទាំងស្រុងមាន ១៤,៦% ករណីយល់ស្របបង្គួរមាន ២០,៧% យល់ស្របតិចតួចមាន ៨,១% និងមិនយល់ស្របមាន ០,៥%។ ជារួមនិស្សិតចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍ទ្រង់ទ្រាយជាករណីសិក្សាមានចំនួន ៧០,៧% ដើម្បីជួយការសិក្សាឆាប់យល់បាន។

- បង្រៀនតាមវិធីជាករណីសិក្សា នាំឲ្យមានការប្រើប្រាស់ឧបករណ៍សិក្សា។ និស្សិតផ្តល់ការយល់ស្របលើក្រាភិកខាងក្រោម ៖

តារាងទី១៧ ការបង្រៀនបែបករណីសិក្សាជាមធ្យោបាយនាំឲ្យប្រើឧបករណ៍សិក្សា




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 1.0 | 5.1 | 21.2 | 48.0 | 24.7 |
| ចំនួន | 2 | 10 | 42 | 95 | 49 |

ការប្រើប្រាស់ឧបករណ៍សិក្សាតាមវិធីបង្រៀនជាករណីសិក្សា និស្សិតមានការយល់ស្របចំនួន ៤៨,០% យល់ស្របទាំងស្រុងមាន ២៤,៧% ករណីយល់ស្របបង្គួរមាន ២១,២% យល់ស្របតិចតួចមាន ៥,១% និងមិនយល់ស្របមាន ១,០%។ ជារួមនិស្សិតចង់បានការប្រើប្រាស់ឧបករណ៍សិក្សាចំនួន ៧២,៧% តាមវិធីបង្រៀនជាករណីសិក្សា ដើម្បីជួយការសិក្សាឆាប់យល់បាន។

**សំណួរទី១០** វិធីបង្រៀនដោយបង្កើតជាក្រុមគម្រោងធ្វើ Assignment លើមុខវិជ្ជាកំពុងសិក្សា និស្សិតផ្តល់កម្រិតការយល់ស្របនៅលើក្រាភិកខាងក្រោមនេះ ៖

- បានរៀនច្រើនម៉ោងពីការបង្កើតជាក្រុមគម្រោងធ្វើ Assignment និស្សិតបានផ្តល់លើកម្រិតយល់ស្របលើក្រាភិកជាបន្តបន្ទាប់ខាងក្រោម ៖

**តារាងទី១៨ បង្កើតក្រុមធ្វើគម្រោង ASSIGNMENT**




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 6.0 | 31.2 | 32.2 | 24.6 | 6.0 |
| ចំនួន | 12 | 62 | 64 | 49 | 12 |

បានរៀនច្រើនម៉ោងតាមវិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment និស្សិតបានផ្តល់លើកម្រិតយល់ស្របចំនួន ២៤,៦% យល់ស្របទាំងស្រុងមាន ៦,0% ករណីយល់ស្របបង្គួរមាន ៣២,២% យល់ស្របតិចតួចមាន ៣១,២% និងមិនយល់ស្របមាន ៦,0%។ ជារួមនិស្សិតយល់ស្របតាមវិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment ក្នុងកម្រិត ៣០,៦% ដើម្បីជួយការសិក្សាឆាប់យល់បាន។

- ចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍តាមវិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment លើមុខវិជ្ជាកំពុងសិក្សា និស្សិតផ្តល់កម្រិតការយល់ស្របនៅលើក្រាភិកខាងក្រោមនេះ៖




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 1.5 | 3.0 | 19.8 | 53.8 | 21.8 |
| ចំនួន | 3 | 6 | 39 | 106 | 43 |

ចង់បានភាគច្រើននៃមេរៀន មានការអនុវត្តន៍តាមវិធីបង្រៀនតាមរបៀបជាការបង្កើតក្រុមគម្រោងធ្វើ Assignment លើមុខវិជ្ជាកំពុងសិក្សា និស្សិតផ្តល់កម្រិតការយល់ស្របមានចំនួន ៥៣,៨% យល់ស្របទាំងស្រុងមាន ២១,៨% ករណីយល់ស្របបង្គួរមាន ១៩,៨% យល់ស្របតិចតួចមាន ៣,០% និងមិនយល់ស្របមាន ១,៥%។ ជារួមនិស្សិតយល់ស្របតាមវិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment ក្នុងកម្រិត ៧៥,៦% ដើម្បីជួយការសិក្សាឆាប់យល់បាន។

- ការប្រើប្រាស់ឧបករណ៍ក្នុងវិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment ក្នុងកម្រិតយល់ស្របលើក្រាភិកខាងក្រោម ៖

តារាងទី២០ ក្រុមធ្វើគម្រោងASSIGNMENT ជាមធ្យោបាយល្អនាំឲ្យប្រើប្រាស់ឧបករណ៍សិក្សា




| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ភាគរយ | 3.1 | 3.1 | 23.1 | 40.0 | 30.8 |
| ចំនួន | 6 | 6 | 45 | 78 | 60 |

ការប្រើប្រាស់ឧបករណ៍សិក្សាក្នុងវិធីបង្រៀន តាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment និស្សិតផ្តល់កម្រិតការយល់ស្របចំនួន ៤០,០% យល់ស្របទាំងស្រុងមានចំនួន ៣០,៨% ករណីយល់ស្របបង្គួរមាន ២៣,១% យល់ស្របតិចតួចមាន ៣,១% និងមិនយល់ស្របមាន ៣,១%។ ជារួមនិស្សិតយល់ស្របតាមវិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment ក្នុងកម្រិត ៧០,៨% ដើម្បីជួយការសិក្សាឆាប់យល់បាន។

**សំណួរទី១១** វិធីបង្រៀនដែលនិស្សិតគិតថាផ្តល់គុណតម្លៃច្រើនចំពោះការសិក្សាបង្ហាញលើក្រាភិកខាងក្រោម ៖

តារាងទី២១ វិធីបង្រៀនដែលផ្តល់គុណតម្លៃច្រើនជាងគេចំពោះការសិក្សា




| | បង្រៀនមេរៀនសុទ្ធ(មេរៀនទី១) | បង្រៀនខ្លះ/ពិភាក្សាខ្លះ(មេរៀនទី២) | បង្រៀនតាមវិធី Jigsaw(មេរៀនទី៣) | បង្រៀនតាមបែបករណីសិក្សា(មេរៀនទី៤) | វិធីបង្រៀនតាមក្រុមធ្វើគម្រោង assignment |
|---|---|---|---|---|---|
| ភាគរយ | .5 | 62.0 | 3.0 | 19.0 | 15.5 |
| ចំនួន | 1 | 124 | 6 | 38 | 31 |

វិធីបង្រៀនខ្លះ/ពិភាក្សាខ្លះមាន ៦២,០% វិធីបង្រៀនតាមបែបករណីសិក្សាមាន ១៩,០% វិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment មាន ១៥,៥% បង្រៀនតាមវិធី Jigsaw មាន ៣,០% និងវីធិបង្រៀនមេរៀនសុទ្ធ ០,៥%។ ជារួមនិស្សិតចង់បានការបង្រៀនតាមវិធីបង្រៀនខ្លះ/ទុកពេលពិភាក្សាខ្លះ គឺជាវិធីដែលមានគុណតម្លៃខ្ពស់ក្នុងការសិក្សា មានន័យថានិស្សិតអាចឆាប់យល់និងទទួលបានពិន្ទុនិទ្ទេសមធ្យម(GPA)ខ្ពស់។ មានមូលហេតុជាច្រើនទៀតដែលនិស្សិតទទួលបានពីវិធីបង្រៀន *បង្រៀនខ្លះ/ពិភាក្សាខ្លះ* គឺធ្វើឲ្យនិស្សិតងាយយល់ទាំងទ្រឹស្តី និងការអនុវត្ត ជម្រុញឲ្យនិស្សិតមានសេចក្តីក្លាហាន កើនបញ្ញាតាមរយៈការចែករំលែកនៅពេលពិភាក្សា ទទួលបានចំណេះដឹងថ្មីៗពីគ្រូ ពីមិត្តរួមថ្នាក់ និងមានកត្តាជាច្រើនដូចជាគំនិតនៃកិច្ចការស្រាវជ្រាវ មានការប្រុងប្រយ័ត្ន(អានឧបសម្ព័ន្ធទី៣)។

**សំណួរទី១២** វិធីបង្រៀនដែលនិស្សិតគិតថាផ្តល់គុណតម្លៃតិចតួចចំពោះការសិក្សាបង្ហាញលើក្រាភិកខាងក្រោម ៖




| | បង្រៀនមេរៀនសុទ្ធ(មេរៀនទី១) | បង្រៀនខ្លះ/ពិភាក្សាខ្លះ(មេរៀនទី២) | បង្រៀនតាមវិធី Jigsaw(មេរៀនទី៣) | បង្រៀនតាមបែបករណីសិក្សា(មេរៀនទី៤) | វិធីបង្រៀនតាមក្រុមធ្វើគម្រោង assignment |
|---|---|---|---|---|---|
| ភាគរយ | 87.0 | 6.0 | 3.5 | 2.5 | 1.0 |
| ចំនួន | 174 | 12 | 7 | 5 | 2 |

វីធិបង្រៀនមេរៀនសុទ្ធ ៨៧,០% វិធីបង្រៀនខ្លះ/ពិភាក្សាខ្លះមាន ៦,០% បង្រៀនតាមវិធី Jigsaw មាន ៣,៥% វិធីបង្រៀនតាមបែបករណីសិក្សាមាន ២,៥% វិធីបង្រៀនតាមរបៀបជាការបង្កើតជាក្រុមគម្រោងធ្វើ Assignment មាន ១,០%។ ជារួមនិស្សិតគិតថាការបង្រៀនតាមវិធីបង្រៀនមេរៀនសុទ្ធជាវិធីដែលមានគុណតម្លៃតិចតួចចំពោះការសិក្សា មានន័យថានិស្សិតយល់បានតិចតួច ឬអាចមិនយល់ និងទទួលបានពិន្ទុនិទ្ទេសមធ្យម(GPA)ទាប។

បន្ថែមលើនេះនិស្សិតបានផ្តល់ការយល់ឃើញថាការបង្រៀនសុទ្ធតែមេរៀនគឺយល់បានខ្លឹមសារតែនៅក្នុងមេរៀន គ្មានភាពទូលំទូលាយ គ្មានគំនិតអ្វីថ្មី ប្លែកសម្រាប់យល់ អង្គុយចាំតែស្តាប់ មានខ្លឹមសារមេរៀនពិបាកយល់ដែលជាហេតុនាំឲ្យធុញនិងរៀនមិនចូល។ តែទោះជាមានគំនិតជំទាស់ក្តីក៏នៅមានការឯកភាពថាការបង្រៀនសុទ្ធតែមេរៀន គឺគ្រូអាចបង្រៀនបាន សិស្សយល់មេរៀនបានល្អ និងអាចមានសមត្ថភាពដែរ(អានឧបសម្ព័ន្ធទី៤)។

**សំណួរទី១៣** និស្សិតចូលចិត្តថ្នាក់រៀនមាននិស្សិតតិច(និស្សិតក្រោម៦០នាក់) ឬថ្នាក់មាននិស្សិតច្រើន(៩០នាក់ឬលើស)។

នៅលើតារាងលទ្ធផលបឋមនៃការធ្វើអង្កេតបង្ហាញពីសេចក្តីពេញចិត្តចំពោះចំនួននិស្សិតក្នុងថ្នាក់រៀនខាងក្រោម ៖

តារាងទី២៣ និស្សិតចូលចិត្តថ្នាក់រៀនមាននិស្សិតតិច ឬថ្នាក់មាននិស្សិតច្រើន

| | ចំនួន | ភាគរយ | ភាគរយបានការ | ភាគរយបង្គ |
|---|---|---|---|---|
| និស្សិតក្រោម៦០នាក់ | 192 | 96.0 | 96.0 | 96.0 |
| ៩០នាក់ឬលើស | 2 | 1.0 | 1.0 | 97.0 |
| មិនចូលចិត្តទាំងពីរ | 6 | 3.0 | 3.0 | 100.0 |
| សរុប | 200 | 100.0 | 100.0 | |

ជារួមនិស្សិតមានសេចក្តីពេញចិត្តរៀននៅក្នុងថ្នាក់ដែលមាននិស្សិតតិចក្រោម៦០នាក់ មានចំនួន ៩៦,០% និងចំនួន ១,០% និស្សិតមានសេចក្តីពេញចិត្តរៀននៅក្នុងថ្នាក់ដែលមាននិស្សិតច្រើនជាង៩០នាក់ ដោយឡែកចំនួន ៣,០% ផ្សេងទៀតមិនចូលចិត្តទាំងពីរករណី។ មូលហេតុដែលនិស្សិតចង់រៀននៅក្នុងថ្នាក់ដែលមាននិស្សិតតិចជាង ៦០នាក់ មានមូហេតុមួយចំនួនដូចជាងាយស្រួលស្តាប់គ្រូពន្យល់ មិនអ៊ូរអរញៀវញ៉ៃ ថ្នាក់រៀនស្ងប់ស្ងាត់ធ្វើឲ្យមានអារម្មណ៍ល្អ ងាយសស្រួលក្នុងការរៀននិងអាចសួរគ្រូបានភ្លាមៗ មានឱកាសច្រើនក្នុងការពិភាក្សាជាមួយមិត្តរួមថ្នាក់និងបង្ហាញសមត្ថភាព និងមានការយកចិត្តទុកដាក់ពីគ្រូបានច្រើន(អានឧបសម្ព័ន្ធទី៥)។

**សំណួរទី១៤** ឥឡូវនិស្សិតកំពុងរៀនថ្នាក់មាននិស្សិតច្រើន(៩០នាក់ឬលើស)។

នៅលើតារាងលទ្ធផលបឋមនៃការធ្វើអង្កេតបង្ហាញពីសេចក្តីពេញចិត្តចំពោះចំនួននិស្សិតក្នុងថ្នាក់រៀនខាងក្រោម ៖

| តារាងទី២៤ ឥទ្ធិពលអ្នកកំពុងរៀននៅក្នុងថ្នាក់មានសិស្សច្រើន(៩០នាក់ ឬ លើស) | | | | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ភាគរយបានការ | ភាគរយបង្គ |
| ត្រឹមត្រូវ(បាទ/ចាំ) | 14 | 7.0 | 7.0 | 7.0 |
| មិនត្រឹមត្រូវ(ទេ) | 186 | 93.0 | 93.0 | 100.0 |
| សរុប | 200 | 100.0 | 100.0 | |

ទោះយ៉ាងណាក្តី នៅលើតារាងលទ្ធផលបឋមបង្ហាញថាមាននិស្សិតចំនួន ៩៣,០% ដែលបច្ចុប្បន្នកំពុងសិក្សានៅក្នុងថ្នាក់ដែលមានចំនួននិស្សិតតិចជាង ៩០នាក់ និង ៧,០% ផ្សេងទៀតកំពុងរៀននៅក្នុងថ្នាក់ដែលមាននិស្សិតយ៉ាងតិច ៩០នាក់។

## IV. លទ្ធផលនៃការស្រាវជ្រាវ

នៅក្នុងផ្នែកពិភាក្សាលទ្ធផលនៃការស្រាវជ្រាវ ជាដំបូងយកមុខវិជ្ជាទាំង១៦ ដែលនិស្សិតបានផ្តល់មកតាមការឆ្លើយក្នុងកម្រងសំណួរមករៀបចំជាបីក្រុមធំៗ ក្រុមទី១ វិទ្យាសាស្រ្តសង្គមមានមុខវិជ្ជាច្បាប់ និងទ្រឹស្តីគ្រប់គ្រងមួយចំនួន ក្រុមទី២ ការអនុវត្តមានមុខវិជ្ជាដែលប្រើប្រាស់ទ្រឹស្តីនិងការគណនាបញ្ចូលគ្នាដូចជាទ្រឹស្តីសេដ្ឋកិច្ច មីក្រូ ម៉ាក្រូសេដ្ឋកិច្ច ទ្រឹស្តីហិរញ្ញវត្ថុ ក្រុមទី៣ វិទ្យាសាស្រ្តពិតដែលមានការគណនាលេខដូចជាគណិតវិទ្យា ស្ថិតិ និងមុខវិជ្ជាគិតលេខមួយចំនួនទៀត។

ជាមួយវិធីបង្រៀនទាំងប្រាំមាន *បង្រៀនមេរៀនសុទ្ធ, បង្រៀនខ្លះ/ ពិភាក្សាខ្លះ, Jigsaw method, បង្រៀនតាមបែបករណីសិក្សា, វិធីបង្រៀនជាក្រុមគម្រោងធ្វើ assignment* នៅលើតារាងខាងក្រោមបង្ហាញពីកម្រិតភាគរយដែលនិស្សិតគិតថាផ្តល់គុណតម្លៃច្រើនដល់ការសិក្សា។

| តារាងទី២៥ វិធីបង្រៀនដែលនិស្សិតគិតថាទទួលបានគុណតម្លៃច្រើនតាមវិទ្យាសាស្រ្តសង្គម ឬវិទ្យាសាស្រ្តពិត | | | | | | | |
|---|---|---|---|---|---|---|---|
| | | បង្រៀនមេរៀនសុទ្ធ | បង្រៀនខ្លះ/ពិភាក្សាខ្លះ | Jigsaw method | បង្រៀនតាមបែបករណីសិក្សា | បង្រៀនជា*ក្រុមគម្រោងធ្វើ assignment* | សរុប |
| វិទ្យាសាស្រ្តសង្គម | ចំនួន | 0 | 56 | 3 | 23 | 17 | 99 |
| | % | .0% | 56.6% | 3.0% | 23.2% | 17.2% | 100.0% |
| ការអនុវត្តន៍ | ចំនួន | 1 | 44 | 2 | 6 | 12 | 65 |
| | % | 1.5% | 67.7% | 3.1% | 9.2% | 18.5% | 100.0% |
| វិទ្យាសាស្រ្តពិត | ចំនួន | 0 | 24 | 1 | 9 | 2 | 36 |
| | % | .0% | 66.7% | 2.8% | 25.0% | 5.6% | 100.0% |
| សរុប | ចំនួន | 1 | 124 | 6 | 38 | 31 | 200 |
| | % | .5% | 62.0% | 3.0% | 19.0% | 15.5% | 100.0% |

វិធីបង្រៀនដែលនិស្សិតចង់បានគឺ ***បង្រៀនខ្លះ/ពិភាក្សាខ្លះ*** ដែលកម្រិតនៃសេចក្តីពេញចិត្តមានរហូតដល់ ៦២,០%។ ***បង្រៀនតាមបែបករណីសិក្សា*** ដែលកម្រិតនៃសេចក្តីពេញចិត្តមាន ១៩,០%

និង *វិធីបង្រៀនជាក្រុមគម្រោងធ្វើ assignment* ដែលកម្រិតនៃសេចក្ដីពេញចិត្តមាន ១៥,៥% ។

## ការស្វែងរកវិធីបង្រៀនដែលនិស្សិតគិតថានឹងទទួលបានពិន្ទុនិទ្ទេសខ្ពស់

**វិធីទី១៖** ប្រៀបធៀបពិន្ទុមធ្យមនៃវិធីបង្រៀនទាំងប្រាំដែលនាំឲ្យនិស្សិតបានពិន្ទុល្អ

ក្នុងដំណើរការស្វែងរកពិន្ទុប្រៀបធៀបនៃវិធីបង្រៀនទាំងប្រាំនេះ តើវិធីបង្រៀនបែបណាដែលមានពិន្ទុប្រៀបធៀបខ្ពស់ជាងគេនោះ តាមបច្ចេកទេសគឺត្រូវប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ SPSS program ដើម្បីជាជំនួនដល់ការគណនាប្រកបដោយទំនុកចិត្ត។ លទ្ធផលនៃការស្រាវជ្រាវបឋមកំណត់លើតារាងវិភាគខាងក្រោមនេះ ៖

តារាងទី២៦ តារាងប្រៀបធៀបវិធីសាស្ត្របង្រៀនដែលនាំឲ្យនិស្សិតទទួលបានពិន្ទុនិទ្ទេសខ្ពស់

| ពិន្ទុនិទ្ទេស | | បង្រៀនមេរៀនសុទ្ធ | បង្រៀនខ្លះ/ ពិភាក្សាខ្លះ | Jigsaw method | បង្រៀនតាមបែបករណីសិក្សា | បង្រៀនជាក្រុមគម្រោងធ្វើ assignment |
|---|---|---|---|---|---|---|
| F ដល់ C | Mean | 0.0000 | **0.7692** | 0.0769 | 0.0000 | 0.1538 |
| | N | 13 | 13 | 13 | 13 | 13 |
| | Std. Deviation | 0.00000 | 0.43853 | 0.27735 | 0.00000 | 0.37553 |
| B ដល់ A | Mean | 0.0000 | **0.5405** | 0.0270 | 0.2703 | 0.1622 |
| | N | 37 | 37 | 37 | 37 | 37 |
| | Std. Deviation | 0.00000 | 0.50523 | 0.16440 | 0.45023 | 0.37368 |
| Total | Mean | 0.0000 | 0.6000 | 0.0400 | 0.2000 | 0.1600 |
| | N | 50 | 50 | 50 | 50 | 50 |
| | Std. Deviation | 0.00000 | 0.49487 | 0.19795 | 0.40406 | 0.37033 |

នៅលើតារាង កម្រិតនៃពិន្ទុប្រៀបធៀបផ្ដល់ដោយកម្មវិធីវិភាគ SPSS program បង្ហាញថា៖

- វិធីបង្រៀនខ្លះ/ ពិភាក្សាខ្លះ មានពិន្ទុ ០,៥៤ ដែលនិស្សិតងាយយល់ និង រំពឹងថានៅពេលប្រឡងនឹងទទួលបានពិន្ទុនិទ្ទេសពី B ដល់ A ។ ការរំពឹងថានៅពេលប្រឡងនឹងទទួលបានពិន្ទុនិទ្ទេសពី F ដល់ C ពិន្ទុប្រៀបធៀបមានកាន់តែធំ ០,៧៧ ។
- វិធីបង្រៀនតាមបែបករណីសិក្សា មានពិន្ទុ ០,២៧ ដែលនិស្សិតងាយយល់ និង រំពឹងថានៅពេលប្រឡងនឹងទទួលបានពិន្ទុនិទ្ទេសពី B ដល់ A ។
- វិធីបង្រៀនជាក្រុមគម្រោងធ្វើ assignment មានពិន្ទុ ០,១៦ ដែលនិស្សិតងាយយល់ និង រំពឹងថានៅពេលប្រឡងនឹងទទួលបានពិន្ទុនិទ្ទេសពី B ដល់ A ។ ការរំពឹងថានៅពេលនឹងទទួលបានពិន្ទុនិទ្ទេសពី F ដល់ C ពិន្ទុប្រៀបធៀបមានកាន់តែធំ ០,១៥ ។

**វិធីទី១នៃការវិភាគ** លទ្ធផលរកឃើញថា វិធីបង្រៀនខ្លះ/ ពិភាក្សាខ្លះ មានគុណតម្លៃច្រើនជាងវិធីបង្រៀនដទៃទៀត និងជាវិធីបង្រៀនមួយដែលនិស្សិតរំពឹងថាអាចនឹងទទួលបានពិន្ទុនិទ្ទេសខ្ពស់ជាងគេ។

**ទិធីទី២៖** យកវិធីបង្រៀនណាមួយធ្វើជាគោលធៀបដើម្បីស្វែងរកវិធីបង្រៀនណាដែលមានអនុបាត(ratio) ខ្ពស់ជាងគេ(ធំជាង១): វិធីបង្រៀននោះមានប្រសិទ្ធភាពនៅថ្នាក់ឧត្តមសិក្សា និងនាំឲ្យនិស្សិតទទួលបានពិន្ទុច្រើន។

កម្មវិធីវិភាគ SPSS program តាមបច្ចេកទេស Binary Logistic លទ្ធផលបង្ហាញថា៖

| តារាងទី២៧ វិធីបង្រៀន | មេគុណ | អត្ថន័យស្ថិតិ |
|---|---|---|
| Jigsaw method | 1.099 | 0.501 |
| បង្រៀនខ្លះ/ ពិភាក្សាខ្លះ | 0.405 | 0.654 |
| បង្រៀនតាមបែបករណីសិក្សា | -20.104 | NS |
| ចំនួនថេរ | 19.699 | 0.999 |
| -2 Log likelihood | Cox & Snell R Square | Nagelkerke R Square |
| 49.961[a] | .137 | .200 |

វិធីបង្រៀន *Jigsaw method* មានមេគុណ 1.099 ជាមួយកម្រិតអត្ថន័យស្ថិតិ 0.501 ក្នុងការទទួលបានពិន្ទុនិទ្ទេសពី B ដល់ A ប្រសើរជាងវិធីបង្រៀន *បង្រៀនខ្លះ/ ពិភាក្សាខ្លះ* មានមេគុណ 0.405 ជាមួយកម្រិតអត្ថន័យស្ថិតិ 0.654 ក្នុងការទទួលបានពិន្ទុនិទ្ទេសពី B ដល់ A ។

**វិធីទី2នៃការវិភាគ** លទ្ធផលបង្ហាញថា ទោះជាវិធីបង្រៀន *បង្រៀនខ្លះ/ ពិភាក្សាខ្លះ* មានប្រសិទ្ធភាពទាបជាងវិធីបង្រៀន *Jigsaw method* តែវាមិនទាន់ឆ្លើយតបនឹងសេចក្តីពេញចិត្តរបស់និស្សិតចំពោះវិធីបង្រៀន *បង្រៀនខ្លះ/ ពិភាក្សាខ្លះ* រហូតដល់ ៦២,០%។

សរុបទាំងពីរករណីនៃការវិភាគទិន្នន័យ លទ្ធផលស្រាវជ្រាវលើការបង្រៀននៅថ្នាក់ឧត្តមសិក្សាបង្ហាញថា រាល់ការបង្រៀនគួរប្រើវិធីបង្រៀន *បង្រៀនខ្លះ/ ពិភាក្សាខ្លះ* គឺមានទំនាក់ទំនងវិជ្ជមានជាកំណើនលីនេអ៊ែរដើម្បីបំពេញទៅតាមសេចក្តីពេញចិត្តរបស់និស្សិត និងបូកផ្សំជាមួយវិធីបង្រៀន *Jigsaw method* សម្រាប់បង្កើនប្រសិទ្ធភាពនៃការបង្រៀនឲ្យកាន់តែមានគុណភាពខ្ពស់ និងជួយនិស្សិតឲ្យទទួលបានចំណេះដឹងកាន់តែប្រសើរ និស្សិតអាចទទួលបានពិន្ទុនិទ្ទេសពី B ដល់ A ក្នុងកម្រិតជឿជាក់ខ្ពស់។



បន្ថែមពីលើវិធីបង្រៀន និស្សិតចង់បានការបង្រៀនឲ្យមានការប្រើប្រាស់ឧបករណ៍សិក្សាសម្រាប់ជួយដល់ការសិក្សាដើម្បីឆាប់យល់ផងដែរ។ ខាងក្រោមនេះជាចំនួនភាគរយនៃការចង់បានរបស់និស្សិតទៅតាមវិធីបង្រៀននីមួយៗ។




នៅលើក្រាបបង្ហាញថា *វិធីបង្រៀនខ្លះ/ ពិភាក្សាខ្លះ* និស្សិតចង់បានការប្រើប្រាស់ឧបករណ៍សិក្សារហូតដល់ ៥១,៥% ក្នុងករណី *វិធីបង្រៀនមេរៀនសុទ្ធ* មានតែ ៣៧,០%។

## V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

វិធីបង្រៀនជាបច្ចេកទេសនៃការផ្ទេរចំណេះ ហើយក៏ជាដំណោះស្រាយចំណោទសិក្សារវាងគ្រូនិងសិស្សផងដែរ។ ការណ៍ដែលគ្រូមានការស្រាវជ្រាវបានល្អលើកិច្ចការបង្រៀន ជាពិសេសទ្រឹស្តីគរុកោសល្យគឺជួយគ្រូឲ្យយល់ដឹងបានទូលំទូលាយលើកិច្ចការបង្រៀន និងការរៀនរបស់សិស្សបានកាន់តែច្បាស់លាស់ ដឹងពីតម្រូវការរបស់និស្សិត ឥរិយាបថ សមត្ថភាព និងការទទួលយកចំណេះដឹងពីគ្រូ។ លទ្ធផលស្រាវជ្រាវលើការបង្រៀននៅថ្នាក់ឧត្តមសិក្សានេះ បានផ្តល់ជាព័ត៌មានមួយអាចទុកចិត្តបានសម្រាប់ធ្វើការសាកល្បង ផ្លាស់ប្តូរបទពិសោធន៍នៃការបង្រៀនជាពិសេសវិធី *បង្រៀនខ្លះ/ ពិភាក្សាខ្លះ* រួមជាមួយវិធីបង្រៀន *Jigsaw method* និងមានប្រើប្រាស់ឧបករណ៍សិក្សាបន្ថែមទៀតដើម្បីបង្កភាពងាយស្រួលដល់និស្សិតឆាប់យល់មេរៀន និងធ្វើកិច្ចការអនុវត្តបានល្អ ហើយនិស្សិតរំពឹងថាអាចនឹងទទួលបានពិន្ទុនិទ្ទេសខ្ពស់។

## VI. ឯកសារយោង

# References


Aivazis, Adriana. 2005. *Basic tips for teachers to structure the classroom environment at the beginning of the year to promote safety and learning for their students.*

Angela Miller & Kathryn Cunningham. 2003. *Classroom Management.*

Brain, Marshall. 2016. *What is good teaching?*

Dunbar, Christopher. 2004. *Tha best pratices in classroom management.* Michigean State University, October.

Forms and Methods of Teaching in Higher Education Institutions. n.d. Accessed 03 18, 2017. gtu.ge/quality/new/en.pdf.

Geraldine O'Neill and Tim McMahon. 2005. *Student-centered learning: what does it mean for students and lestures?* University College Dublin.

Hattie, Jonh. 2017. *5 Highly effective teaching pratices.* 2 27.

Hildebrand, M. 1971. *Characteristics of effective teachers.*

Kenyon, Bobbi Jo. 2007. *Classroom management.* ASIAEUNIVERSITY.

Laursen, Martin Holmgaard. 2017. *Abduction, Induction and deduction in pedacogics.* 3 11.

Milkova, Stiliana. 2016. *Strategies for effective lesson planing.* Center for reseaarch on learning and teaching, August 23.

Robert G. Croninger & Linda Valli. 2012. "Analises of teaching quality." *Seminar in Mixed Method.* 1.

Robert Smith, Ph.D. & Scott Imig, Ph.D. 2014. *Quality Teachers: Do experience and education matter?* University of North Carolina Wilmington.

Stremmel, Andrew J. 2002. *The value of teacher research: Nurturing professtional and personal growth inquiry.* September.

Teacher-Centered vs Student-centered Education. 2012. *http://education.cu-portland.edu./category/blog/classroom-resources/.* 12 31. Accessed 1 6, 2016.

Thiyagu, Dr. K. 2011. *Methods of teaching mathematic.* Central University of Tamilnadu, Thiruvarur, 5 20.

ប្រាជ្ញពិជ័យ និង ឌុំជារុធ. ២០១៥. *សិល្បៈនៃការបង្រៀន.* ភ្នំពេញ.គ្រឹះស្ថានបោះពុម្ពផ្សាយដើមអំពិល :

## 6. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធទី១

### កម្រងសំណួរស្រាវជ្រាវ

១. មុខវិជ្ជា………………………………………………………………………………………….

២. និស្សិតរៀននៅឆ្នាំ 1.☐ ទី១, 2. ☐ ទី២, 3. ☐ ទី៣, 4. ☐ ទី៤, 5. ☐ បរិញ្ញាបត្រជាន់ខ្ពស់

៣. ភេទ 1. ☐ ប្រុស, 2. ☐ ស្រី

៤. កម្រិតនិទ្ទេសរំពឹងទុកដែលអ្នកអាចនឹងទទួលបានលើមុខវិជ្ជានេះ

**1.☐ A, 2.☐ B, 3.☐ C, 4.☐ D, 5.☐ E, 6.☐ F**

៥. ចូរបង្ហាញកម្រិតយល់ស្របជាមួយឃ្លាបន្តបន្ទាប់ ហើយគូស " √ " នៅក្នុងប្រអប់។

| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| នេះជាមុខវិជ្ជាដែលមានសារៈសំខាន់ខ្លាំង | | | | | |
| ខ្ញុំបានសិក្សាស្វែងយល់មុខវិជ្ជានេះច្រើនម៉ោង | | | | | |
| ខ្លឹមសារដែលមានក្នុងមុខវិជ្ជានេះមានសារៈសំខាន់ខ្លាំង | | | | | |
| បើប្រៀបធៀបនឹងមុខវិជ្ជាផ្សេង វាមានភាពងាយស្រួលដល់ខ្ញុំ | | | | | |
| ជារួម ខ្ញុំយល់ថាការដាក់Assignment និងកិច្ចការផ្សេងៗនៃមុខវិជ្ជានេះ គឺមានប្រយោជន៍ច្រើន | | | | | |

៦. នៅ**មេរៀនទី១**នៃមុខវិជ្ជាៈ មាតិកាមេរៀននេះគឺបានបង្ហាញពីទម្រង់បង្រៀនសុទ្ធ(គ្មានពិភាក្សាក្រុម ឬសកម្មភាពផ្សេងៗក្នុងពេលសិក្សា)។ចូរដាក់កម្រិតយល់ស្របឃ្លាបន្តបន្ទាប់ ដោយគូស " √ " នៅក្នុងប្រអប់។

| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ខ្ញុំបានរៀនច្រើនម៉ោង ករណីបង្រៀនសុទ្ធតែមេរៀន | | | | | |
| ខ្ញុំចង់ឲ្យមានការអនុវត្តន៍ខ្លះនៅក្នុងទម្រង់នៃការបង្រៀនតែមេរៀនសុទ្ធបែបនេះ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ទម្រង់នៃការបង្រៀនសុទ្ធជាមធ្យោបាយល្អសម្រាប់សម្រាប់ឲ្យខ្ញុំឈានទៅប្រើឧបរណ៍សិក្សា | | | | | |

**៧.** នៅ**មេរៀនទី២**នៃមុខវិជ្ជា: មាតិកាមេរៀននេះគឺបានបង្ហាញពីទម្រង់បង្រៀនសុទ្ធ/ទម្រង់ពិភាក្សា(ការបង្រៀនច្រើន និងផ្តល់ពេលខ្លះឲ្យពិភាក្សាជាក្រុម)។ចូរផ្តល់កម្រិតយល់ស្របឃ្លាបន្តបន្ទាប់ដោយគូស " √ " នៅក្នុងប្រអប់។

| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ខ្ញុំបានរៀនមេរៀនច្រើនម៉ោង /បានពិភាក្សាផ្នែកខ្លះនៃមេរៀននេះ | | | | | |
| ខ្ញុំចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍ខ្លះនៅក្នុងទម្រង់បង្រៀនសុទ្ធ/ មានការពិភាក្សាខ្លះ | | | | | |
| ការបង្រៀនសុទ្ធ/ ការពិភាក្សាខ្លះ ជាមធ្យោបាយល្អសម្រាប់ឲ្យខ្ញុំឈានទៅប្រើឧបរណ៍សិក្សា | | | | | |

**៨.** នៅ**មេរៀនទី៣**នៃមុខវិជ្ជា: មាតិកាមេរៀននេះគឺបានបង្ហាញពីទម្រង់បង្រៀនបែប Jigsaw (jigsaw strategy) ។ ចូរបង្ហាញកម្រិតយល់ស្របជាមួយឃ្លាបន្តបន្ទាប់ ដោយគូស " √ " នៅក្នុងប្រអប់។

| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ខ្ញុំបានរៀនមេរៀនតាមវិធី Jigsaw ច្រើនម៉ោងក្នុងផ្នែកខ្លះនៃមេរៀននេះ | | | | | |
| ខ្ញុំចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍តាមវិធី Jigsaw | | | | | |
| ការបង្រៀនតាមវិធី Jigsaw ជាមធ្យោបាយល្អសម្រាប់ឲ្យខ្ញុំឈានទៅប្រើឧបរណ៍សិក្សា | | | | | |

**៩.** នៅ**មេរៀនទី៤**នៃមុខវិជ្ជា: មាតិកាមេរៀននេះ គឺប្រើវិធីសាស្ត្របង្រៀនជា(បែប)ករណីសិក្សា។ចូរបង្ហាញកម្រិតយល់ស្របជាមួយឃ្លាបន្តបន្ទាប់ ដោយគូស " √ " នៅក្នុងប្រអប់។

| | មិនយល់ស្រប | យល់ស្របតិចតួច | យល់ស្របបង្គួរ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ខ្ញុំបានរៀនករណីសិក្សាច្រើនម៉ោង លើផ្នែកខ្លះនៃមេរៀននេះ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ខ្ញុំចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍នៅក្នុងទ្រង់ទ្រាយជាករណីសិក្សា | | | | | |
| ការបង្រៀនបែបករណីសិក្សា ជាមធ្យោបាយល្អសម្រាប់ឲ្យខ្ញុំឈានទៅប្រើឧបរណ៍សិក្សា | | | | | |

**១០.** បន្ថែមលើការសិក្សាកម្មវត្ថុសម្រាប់មេរៀននីមួយៗក្នុងសៀវភៅសិក្សា(textbook), មុខវិជ្ជានេះតម្រូវឲ្យមានការញែកកម្មវត្ថុសិក្សាផ្សេងៗគ្នា(ឧទាហរណ៍ ដូចជាអានតែត្រង់កន្លែងទ្រឹស្តីសហគ្រាស/ ព័ត៌មានសហគ្រាស ឬ អានរបៀបដកស្រង់ឯកសារយោង APA style ជាដើម)។វិធីបង្រៀន គឺបង្កើតជា(ឬតាមរបៀប)*ក្រុមគម្រោងធ្វើ assignment* (Team project assignment)បានអនុវត្តតាមសភាពភាពផ្សេងគ្នានេះ។ចូរបង្ហាញកម្រិតយល់ស្របក្រុម*គម្រោងធ្វើ assignment* ជាមួយឃ្លាបន្តបន្ទាប់ ដោយគូស " √ " នៅក្នុងប្រអប់។

| | មិនយល់ស្រប | យល់ស្រប តិចតួច | យល់ស្រប បង្គួរ | យល់ស្រប | យល់ស្រប ទាំងស្រុង |
|---|---|---|---|---|---|
| ខ្ញុំបានរៀនច្រើនម៉ោង ពីការបង្កើតក្រុមធ្វើគម្រោង assignment សម្រាប់មុខវិជ្ជានេះ | | | | | |
| ខ្ញុំចង់បានភាគច្រើននៃមេរៀនមានការអនុវត្តន៍ ដើម្បីយល់របៀបរៀនបែប *ក្រុមគម្រោងធ្វើ assignment* | | | | | |
| បង្រៀនបែប *ក្រុមគម្រោងធ្វើ assignment* ជាមធ្យោបាយល្អសម្រាប់ឲ្យខ្ញុំឈានទៅប្រើឧបរណ៍សិក្សា | | | | | |

**១១.** នៅក្នុងគំនិតរបស់អ្នក ដើម្បីបំពេញគោលបំណងក្នុងការសិក្សា, តើវិធីសាស្រ្តបង្រៀនបែបណាដែល**ផ្តល់គុណតម្លៃច្រើន**សម្រាប់អ្នក? ដោយផ្ទាល់ខ្លួន, ចូរជ្រើសរើសយកតែវិធីសាស្រ្តមួយគត់។

1. ☐ បង្រៀនមេរៀនសុទ្ធ (មេរៀនទី១) 2. ☐ បង្រៀនខ្លះ/ ពិភាក្សាខ្លះ(មេរៀនទី២)

3. ☐ Jigsaw method (មេរៀនទី៣) 4. ☐ បង្រៀនតាមបែបករណីសិក្សា(មេរៀនទី៤)

5. ☐ វិធីបង្រៀនជា (តាមរបៀប) *ក្រុមគម្រោងធ្វើ assignment* (Team project assignment)

ហេតុអ្វី?……………………………………………………………………………………………………

……………………………………………………………………………………………………

**១២.** នៅក្នុងគំនិតរបស់អ្នក, តើវិធីសាស្រ្តបង្រៀនបែបណាដែល**មានគុណតម្លៃតិចតួច**ចំពោះការសិក្សារបស់អ្នក? ដោយផ្ទាល់ខ្លួន, ចូរជ្រើសរើសយកវិធីសាស្រ្តតែមួយគត់។

1. ☐ បង្រៀនមេរៀនសុទ្ធ (មេរៀនទី១) 2. ☐ បង្រៀនខ្លះ/ ពិភាក្សាខ្លះ(មេរៀនទី២)

3. ☐ Jigsaw method (មេរៀនទី៣) 4. ☐ បង្រៀនតាមបែបករណីសិក្សា(មេរៀនទី៤)

5. ☐ វិធីបង្រៀនជា(តាមរបៀប) *ក្រុមគម្រោងធ្វើ assignment* (Team project assignment)

ហេតុអ្វី?……………………………………………………………………………………………………

………………………………………………………………………………………………………………………

**១៣.** តើអ្នកចូលចិត្តថ្នាក់រៀនមានសិស្សតិច(សិស្សក្រោម៦០នាក់) ឬ ថ្នាក់មានសិស្សច្រើន(៩០នាក់ ឬលើស)?

1. □ ថ្នាក់មានសិស្សតិច 2. □ ថ្នាក់មានសិស្សច្រើន 3. □ មិនចូលចិត្ត

ហេតុអ្វី?……………………………………………………………………………………………………

………………………………………………………………………………………………………………………

**១៤.** តើឥឡូវអ្នករៀននៅក្នុងថ្នាក់មាននិស្សិតច្រើន(៩០នាក់ ឬលើស) មែនឬទេ?

1. □ បាទ/ចាស 2. □ ទេ

## ឧបសម្ព័ន្ធទី២

## ចំនួនមុខវិជ្ជាដែលនិស្សិតម្នាក់សិក្សា និងផ្តល់ការវាយតម្លៃលើវិធីបង្រៀនរបស់គ្រូ

| | | | |
|---|---|---|---|
| 1. Methodology of research<br>2. Investment<br>3. Finance<br>4. Accounting | 5. Micro, International eco, Inter trade<br>6. Macroeconomics<br>7. Leader Ship<br>8. Stat, math, Econometrics | 9. Management<br>10.Business law<br>11.Land law<br>12.Public Law | 13.Civil law<br>14.Criminal law<br>15.Constitutional law<br>16.Labor law |

## ឧបសម្ព័ន្ធទី៣

## សំណួរទី១១ មូលហេតុនៃវិធីសាស្ត្របង្រៀនដែលមានគុណតម្លៃខ្ពស់ដល់ការសិក្សា

- ពន្យល់នូវអ្វីដែលថ្មីសិស្សមិនទាន់ដឹង និងអាចបញ្ចេញមតិបាន (មាន ១០ ករណី)
- អាចយកករណីទិដ្ឋភាពជាក់ស្តែងវិភាគ និង ពិភាក្សា
- ការពិភាក្សាអាចជម្រុញឲ្យសិស្សមានភាពក្លាហាន និង កើនបញ្ញា(មាន ១០ ករណី)
- ការបង្រៀនបូកផ្សំជាមួយការពិភាក្សាធ្វើឲ្យសិស្សងាយយល់ខ្លឹមសារមេរៀន(មាន ៥ករណី)
- អាដឹងថាមានសិស្សខ្លះយល់ និងសិស្សខ្លះមិនទាន់យល់(មាន២ករណី)
- ទទួលបានចំណេះដឹងថ្មីៗពីគ្រូ និងមិត្តរួមថ្នាក់ (មាន ១២ ករណី)
- អាចបញ្ចេញការយល់ឃើញ ចោទសួរនិងពិភាក្សា (មាន ៣ករណី)
- និស្សិតឆាប់យល់ ចេះធ្វើការងារក្រុមក្រោយបញ្ចប់ការសិក្សា (មាន ១១ករណី)
- ការបង្រៀនមានភាពទាក់ទាញដល់និស្សិតឲ្យបញ្ចេញគំនិតលើការអនុវត្តទ្រឹស្តី និងឆាប់យល់មេរៀនជាងការទន្ទេញចាំតែទ្រឹស្តី (មាន ១៣ករណី)
- អាចពិភាក្សាលើចំនុចខ្វះខាត អាចពិភាក្សាជាក្រុមមានគំនិតច្រើនបញ្ចូលគ្នា (មាន៣ករណី)
- អាចមានការបញ្ចេញមតិ និងមានគំនិតលូតលាស់ច្រើន(មាន ៩ករណី)

- ទទួលបានចំណេះដឹង និងបទពិសោធន៍ពីការពិភាក្សា (មាន ១១ករណី)
- យល់ទាំងទ្រឹស្តី និងការអនុវត្តន៍ថែមទៀត (មាន ១៨ករណី)
- មានការយល់ដឹងកាន់តែច្បាស់ក្នុងការងារអនុវត្តន៍ (មាន ៧ករណី)
- យល់ដឹងទិដ្ឋភាពជាក់ស្តែងនៃមេរៀនក្នុងការអនុវត្តន៍ និង វិភាគ (មាន ២ករណី)
- ចែករំលែកចំណេះដឹងគ្នាទៅវិញទៅមក និងបំពេញចំនុចខ្វះខាត (មាន ៩ករណី)
- យល់មេរៀន ចេះធ្វើការងារជាក្រុម និងអាចយល់លើចំនុចដែលមិនទាន់យល់
- ផ្តល់គំនិតច្រើនដល់កិច្ចការស្រាវជ្រាវ និងមានការប្រុងប្រយ័ត្ន (មាន ១៣ករណី)
- បានចូលរួមគំនិតជាមួយគ្រូ និងប្រើខួរក្បាលច្រើន
- បានបញ្ចេញគំនិតទាំងអស់គ្នា យល់ស្រប ឬមិនយល់ស្រប
- មានគំនិតផ្ទាល់ខ្លួន និងសួរឆ្លើយជាមួយគ្រូ
- ប្រឹងប្រែងរៀនសូត្រដើម្បីឈានទៅរកឧត្តមភាព (មាន ២ករណី)
- សួរបានភ្លាមៗ (មាន ៥ករណី)
- ចែករំលែកចំណេះដឹង ពន្យល់ បកស្រាយ និង ត្រិះរិះ (មាន ២ករណី)
- សប្បាយរីករាយក្នុងការសិក្សា និងទទួលបានគំនិតផ្សេងៗ (មាន ៥ករណី)
- អាចដឹងបញ្ហា និងដំណោះស្រាយជាក់ស្តែងដែលបានជួបប្រទះ (មាន ៦ករណី)
- ជួយដល់សិស្សខ្សោយ និងជាការប្រឹក្សាដល់សិស្សពូកែ
- ផ្លាស់ប្តូរមតិគ្នានាំឲ្យឆាប់យល់ (មាន ២ករណី)

**ឧបសម្ព័ន្ធទី៤**

**សំណួរទី១២ មូលហេតុនៃវិធីសាស្រ្តបង្រៀនដែលមានគុណតម្លៃតិចដល់ការសិក្សា**

- ព្រោះគ្រូអាចបង្រៀនបាន និងសិស្សអាចមានសមត្ថភាពដែរ (មាន ៣ករណី)
- យល់តែមេរៀនគ្មានការអនុវត្តនាំឲ្យមានការសិក្សាម្តងទៀតពេលទៅធ្វើការ
- ពន្យល់តែមេរៀនធ្វើឲ្យសិស្សធុញ និងរៀនមិនចូល (មាន ៨ករណី)
- វាដូចជាអានសៀវភៅឲ្យសិស្សស្តាប់ (មាន ២ករណី)
- គ្មានការអនុវត្តន៍ជាក់ស្តែងពិបាកក្នុងការយល់ (មាន ៣ករណី)
- គ្មានការអនុវត្តន៍សិស្សខ្លះទៅស្តាប់គ្រាន់យកតែវត្តមាន សិស្សខ្លះមិនយកចិត្តទុកដាក់ក្នុងការរៀន ជាពិសេសខ្វះការពិភាក្សា (មាន ៣ករណី)
- មិនដឹងបញ្ហាផ្សេងៗក្រៅពីមេរៀន (មាន ៣ករណី)
- មានភាពធុញទ្រាន់ ពិបាកយល់ខ្លឹមសារមេរៀនបានគ្រប់ជ្រុងជ្រោយ (មាន ៤ករណី)

- មិនអាចស្វែងយល់ចំនុចផ្សេងៗទៀត គ្មានការពិភាក្សា គ្មានរៀបចំគម្រោង (មាន ៧ករណី)
- គ្មានភាពទូលំទូលាយ ធុញថប់(stress) (មាន ៣២ករណី)
- មានការពិភាក្សាទើបទទួលបានចំណេះដឹងច្រើន (មាន ២ករណី)
- គ្មានគំនិតអ្វីសម្រាប់យល់ អង្គុយចាំតែស្តាប់ (មាន ២៨ករណី)
- យល់មិនសូវស៊ីជម្រៅ និងមិនដឹងចំនុចខ្វះចន្លោះ (មាន ៨ករណី)
- យល់តែមេរៀន មិនចេះអនុវត្ត មិនអាចយកទៅប្រើប្រាស់បាន (មាន ៦ករណី)
- យល់តែក្នុងមេរៀន (មាន ៨៨ករណី)
- មានការពិភាក្សាប្តូរយោបល់ ទើបចេះធ្វើការជាក្រុម (មាន ២ករណី)
- មិនបានផ្តល់មេរៀន និងព័ត៌មានច្បាស់លាស់ (មាន ១០ករណី)
- គ្មានហេតុផលផ្សេងៗក្រៅពីករណីសិក្សា គ្មានការស្រាវជ្រាវ (មាន ៥ករណី)
- ចំណាយពេលច្រើនក្នុងការស្វែងយល់មេរៀន
- បិទសិទ្ធិក្នុងការសួរលើចំនុចណាឆ្ងល់ (មាន ៣ករណី)

**ឧបសម្ព័ន្ធទី៥**

**សំណួរទី១៣ មូលហេតុនៃការរៀនថ្នាក់មាននិស្សិត តិច ឬច្រើន**

- មិនមានភាពអ៊ូរអរ ឡូឡា និយាយស្រួលស្តាប់ (មាន ៦ករណី)
- ងាយស្រួលដល់ការសួរសំណួរ និងពិភាក្សាលើករណីសិក្សា
- ងាយស្រួលក្នុងការគ្រប់គ្រង និងអាចបង្រៀនប្រកបដោយប្រសិទ្ធភាព
- ងាយស្រួលស្តាប់គ្រូពន្យល់ សួរសំណួរបានច្រើន (មាន ៣ករណី)
- សិស្សច្រើនពេកពិបានបង្រៀន និងពិបាកគ្រប់គ្រង (មាន ២ករណី)
- មានឱកាសច្រើនក្នុងការពិភាក្សាជាមួយមិត្តរួមថ្នាក់ (មាន ២ករណី)
- ងាយស្រួលមើល ស្តាប់ និងការយកចិត្តទុកដាក់ពីគ្រូ
- ស្ងប់ស្ងាត់ និងមានឱកាសសួរបានច្រើន
- មិនរញ៉េរញ៉ៃ ការបង្រៀនមានភាពតឹងរឹង (មាន ៣ករណី)
- បរិយាកាសក្នុងថ្នាក់ល្អ មិនរញ៉េរញ៉ៃ ថ្នាក់រៀនស្ងប់ស្ងាត់ធ្វើឲ្យមានអារម្មណ៍ល្អ
- បង្កភាពងាយស្រួលដល់ការរៀន និងការបង្រៀន(មាន ៩ករណី)
- ងាយស្រួលស្តាប់ សរសេរ សួរ គ្មានភាពរញ៉េរញ៉ៃ (មាន ៣១ករណី)
- មានការពិភាក្សា និងសួរគ្រូបានច្រើន(មាន ៣ករណី)
- ចូលចិត្ត និងមានភាពងាយស្រួលរៀនក្នុងថ្នាក់មានសិស្សក្រោម ៥០នាក់ (មាន ៧ករណី)

- ងាយ/ អាចស្តាប់គ្រូពន្យល់បានច្បាស់ល្អ (មាន ១៦ករណី)
- ងាយស្រួលគ្រប់គ្រង និងមានឱកាសបង្ហាញសមត្ថភាព(មាន ៥ករណី)
- ងាយស្រួលចែកក្រុមការងារ និងមានឱកាសសួរគ្រប់ៗគ្នា(មាន ១៥ករណី)
- ងាយស្រួលក្នុងការរៀន និងអាចសួរភ្លាមៗ(មាន ៩៦ករណី)
- ពិបានស្តាប់គ្រូពន្យល់ និងចំណាយពេលធ្វើកិច្ចការច្រើន(មាន ៩ករណី)
- មានប្រសិទ្ធភាពខ្ពស់(មាន ៧ករណី)
- ស្គាល់មនុស្សច្រើន ទទួលបានមិត្តភាព និងទទួលបានគំនិតផ្សេងៗ។